ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ឆ្នាំ ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
13 / 09 / 2012
ម៉ោង (Time/Heure) : 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

ចំពោះមុខ

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូរ ឧត្តារា

កាលបរិច្ឆេទ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២
ភាសាដើម ខ្មែរ/អង់គ្លេស/បារាំង
ប្រភេទឯកសារ សាធារណៈ:

# សេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្តីសម្រេច របស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

អៀង ធីរិទ្ធ

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

ផាត់ ពៅស៊ាង
Diana ELLIS

## ១. សេចក្តីផ្តើម

១. បន្ទាប់ពីមានបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា លើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ដែលបានប្រកាសថា ជនជាប់ចោទ អៀង ធីរិទ្ធ ពុំមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ និងដែលបានបង្គាប់ឱ្យដោះលែងជនជាប់ចោទជាបន្ទាន់ អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បានផ្អាកការដោះលែងជនជាប់ចោទ ហើយបានបញ្ជូនបញ្ហាសម្បទាខាងបញ្ញាស្មារតីដើម្បីចូលរួមសវនាការរបស់ជនជាប់ចោទ ត្រឡប់មកអង្គជំនុំជម្រះសាលាដំបូងវិញ។ អនុលោមតាមការបង្គាប់របស់ អ.ជ.ត.ក ដែលថាត្រូវតែប្រើប្រាស់គ្រប់វិធានការទាំងអស់ ដើម្បីធ្វើឱ្យជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមការជំនុំជម្រះ អ្នកជំនាញវេជ្ជសាស្ត្រដែលតុលាការបានតែងតាំង បានផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងការព្យាបាលឡើងវិញ។ ភ្លាមៗបន្ទាប់ពីអនុវត្តតាមអនុសាសន៍នៃការព្យាបាលរួចហើយ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យមានការវាយតម្លៃឡើងវិញ អំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទដើម្បីចូលរួមក្នុងការជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចនេះ បន្ទាប់ពីបានពិចារណាអំពីលទ្ធផលនៃការវាយតម្លៃឡើងវិញរបស់អ្នកជំនាញ ព្រមទាំងសក្ខីកម្មរបស់អ្នកជំនាញ និងសេចក្តីសន្និដ្ឋានរបស់ភាគី នៅអំឡុងពេលសវនាការកាលពីថ្ងៃទី ៣០ និងថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២។

## ២. ប្រវត្តិនីតិវិធី

២. កាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ផ្អែកតាមការសន្និដ្ឋានជាឯកច្ឆន្ទរបស់អ្នកជំនាញវេជ្ជសាស្ត្រចំនួន ០៥ រូបដែលតុលាការបានតែងតាំងដែលថា ជនជាប់ចោទ អៀង ធីរិទ្ធ កំពុងទទួលរងស្ថានភាពនៃការធ្លាក់ចុះបញ្ញាស្មារតីដែលចេះតែវិវឌ្ឍន៍ទៅមុខ (អាចជាជំងឺ Alzheimer) អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា គាត់ពុំមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ដើម្បីចូលរួមសវនាការនោះទេ[1]។ ជាលទ្ធផល អង្គជំនុំជម្រះបានបំបែកការចោទប្រកាន់ទាំងអស់ប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ និងបានផ្អាកនីតិវិធីប្រឆាំងនឹងរូបគាត់។ បន្ទាប់ពីពុំមានការយល់ស្រប

[1] សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ឯកសារលេខ E138 ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើកទីមួយស្តីពីសម្បទាក្នុងការចូលរួមសវនាការ"), កថាខណ្ឌ ៥២ ដល់ ៥៣ ទំព័រ ៥៩។



jt RA

គ្មានអំពីបច្ច័យដែលអាចមាន ចំពោះការរកឃើញថា ជនជាប់ចោទមិនមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការនោះ អង្គជំនុំជម្រះសាលាដំបូងបានជ្រើសរើសយកការសម្រេចមួយដែលផ្ដល់ប្រយោជន៍ច្រើនបំផុតដល់ជនជាប់ចោទ និងបានបង្គាប់ឱ្យដោះលែងជនជាប់ចោទ ដោយឥតលក្ខខណ្ឌ[2]។

៣. បន្ទាប់ពីមានបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាលើបញ្ហានៃការដោះលែងនេះ អង្គជំនុំជម្រះតុលាការកំពូល នៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ បានបដិសេធការបង្គាប់ឱ្យដោះលែងរបស់អង្គជំនុំជម្រះសាលាដំបូង ដោយបានសម្រេចថា "ការដោះលែងជនជាប់ចោទដោយគ្មានលក្ខខណ្ឌ គឺមិន "តម្រូវឱ្យមាន" ឡើយនៅក្នុងបរិបទនៃការផ្អាកកិច្ចដំណើរការនីតិវិធី ដែលអាចបន្តនីតិវិធីទៀតបាន"[3]។ អ.ជ.ត.ក ក៏បានសម្រេចទៀតថា វិធានការដើម្បីធ្វើឱ្យសមត្ថភាពបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ មានភាពល្អប្រសើរ ពុំទាន់ត្រូវបានប្រើប្រាស់ទាំងអស់នៅឡើយទេ ដោយ អ.ជ.ត.ក បានគូសបញ្ជាក់ថា "ជាបឋម អង្គជំនុំជម្រះសាលាដំបូងគួរតែបានវាយតម្លៃម៉ត់ចត់អំពីរាល់អត្ថប្រយោជន៍ និងថ្លឹងថ្លែងឱ្យបានត្រឹមត្រូវរាល់កត្តាពាក់ព័ន្ធ" មុនពេលដោះលែងជនជាប់ចោទ[4]។ ជាលទ្ធផល អ.ជ.ត.ក បានធ្វើបដិសេធដីការបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ និងបានណែនាំអង្គជំនុំជម្រះសាលាដំបូងឱ្យធ្វើការព្យាបាលបន្ថែម ដោយមានការពិគ្រោះយោបល់ជាមួយអ្នកជំនាញវេជ្ជសាស្ត្រ។ អ.ជ.ត.ក ក៏បានបង្គាប់ទៀតថា "ល្ដឹកណាជនជាប់ចោទនៅស្ថិតក្រោមការឃុំឃាំង ត្រូវឃុំខ្លួនជនជាប់ចោទនៅក្នុងមន្ទីរពេទ្យ ឬកន្លែងសមស្របដទៃទៀត" និងជំរុញឱ្យអង្គជំនុំជម្រះសាលាដំបូង "ប្រុងប្រយ័ត្នថា ការបន្តឃុំខ្លួនណាមួយនឹងមិនមានក្នុងគោលបំណងយូរអង្វែង ដែលជាការរំលោភលើសិទ្ធិមនុស្ស ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ"[5]។

៤. នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឱ្យមានការផ្ដល់អនុសាសន៍ ដែលសមស្របតាមក្បួនវេជ្ជសាស្ត្រ ដើម្បីអនុវត្តសេចក្ដីសម្រេចរបស់ អ.ជ.ត.ក អ្នកជំនាញវេជ្ជសាស្ត្របានចង្អុល

2 សេចក្ដីសម្រេចលើកទីមួយស្ដីពីសម្បទាក្នុងការចូលរួមសវនាការ កថាខណ្ឌ ៧៩ ដល់ ៨១។

3 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ឯកសារលេខ E138/1/7 ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ("សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្ដឹងសាទុក្ខភ្លាមៗ") កថាខណ្ឌ ២៥ (សេចក្ដីបញ្ជាក់លើឯកសារដើម)។

4 សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្ដឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៣០ កថាខណ្ឌ ៤៣។

5 សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្ដឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៣០ និងផ្នែកសេចក្ដីសម្រេច។

00846937

បង្ហាញនូវវិធានការចំនួនពីរ ដែលអាចធ្វើឱ្យមុខងារបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ មានភាពល្អប្រសើរ៖ (១) ការកាត់បន្ថយការប្រើប្រាស់ឱសថ Bromazepam បន្តិចម្តងៗ (ឱសថនេះក៏ត្រូវបានគេស្គាល់ថា Lexomil) និង (២) ការប្រើប្រាស់ថ្នាំបិតព្យាបាល Rivastigmine[6]។ អ្នកជំនាញបានណែនាំឱ្យមានការព្យាបាលតាមរយៈការលើកកម្ពស់បញ្ញាស្មារតី (*ដូចជា* ការព្យាបាលដោយចលនា) ដើម្បីបំពេញបន្ថែមពីលើរបបព្យាបាលនេះ បើទោះបីជាមានការកត់សម្គាល់ផ្នែកវេជ្ជសាស្ត្រថា ពុំមានភស្តុតាងជាក់ស្តែងណាមួយ ដើម្បីសន្និដ្ឋានថា ការព្យាបាលដោយចលនាតែមួយមុខអាចធ្វើឱ្យប្រែប្រួលដល់ការធ្លាក់ចុះនៃបញ្ញាស្មារតីក៏ដោយ[7]។ អ្នកជំនាញវេជ្ជសាស្ត្របានគូសបញ្ជាក់ថា ការព្យាបាលដោយឱសថ Rivastigmine រយៈពេលចំនួន១៨ សប្តាហ៍ និងការព្យាបាលដោយចលនារយៈពេលចំនួន ៣ ខែ នឹងគ្រប់គ្រាន់ដើម្បីបង្ហាញអំពីប្រសិទ្ធភាពជាក់ស្តែងនៃការព្យាបាលនេះ[8]។

៥. គ្រូពេទ្យមួយរូបដែលព្យាបាលជនជាប់ចោទ អៀង ធីរិទ្ធ វេជ្ជបណ្ឌិត ចក ធីតា បានរាយការណ៍ថា ឱសថ Lexomil ត្រូវបានកាត់បន្ថយចំនួន ១ ភាគបួន ជារៀងរាល់សប្តាហ៍ ចាប់ពីថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១២ ហើយការប្រើប្រាស់ឱសថនេះត្រូវបានបញ្ឈប់ទាំងស្រុង នៅថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១២[9]។ ការព្យាបាលដោយឱសថ Rivastigmine បានចាប់ផ្តើមកាលពីថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២។ ហេតុដូច្នេះ អៀង ធីរិទ្ធ បានទទួលការព្យាបាលនេះចំនួន ១៨ សប្តាហ៍ គិតត្រឹមថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២[10]។ ដោយហេតុថា នៅប្រទេសកម្ពុជាពុំមានគ្រូពេទ្យព្យាបាលដោយ

---

[6] របាយការណ៍ទាក់ទងនឹង លោកស្រី អៀង ធីរិទ្ធ ដាក់ជូនតាមសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E138/1/7/4, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៨។

[7] ចម្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងអនុសាសន៍របស់អ្នកជំនាញវេជ្ជសាស្ត្រ E138/1/7/7, ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២។

[8] របាយការណ៍ទាក់ទងនឹងលោកស្រី អៀង ធីរិទ្ធ ដាក់ជូនតាមសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០៦ ខែមករា ឆ្នាំ ២០១២, E138/1/7/4 ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ("អនុសាសន៍របស់អ្នកជំនាញ") កថាខណ្ឌ ៨ (ដែលក្រោយមកត្រូវបានកែសម្រួល ដោយផ្អែកលើចម្លើយតបរបស់អ្នកជំនាញ តបទៅនឹងការត្រួតពិនិត្យ ទាក់ទងនឹងរយៈពេលនៃការព្យាបាលឱសថបិតព្យាបាល និងរយៈពេលសម្រាប់ការវាយតម្លៃឡើងវិញលើសម្បទាក្នុងការចូលរួមសវនាការរបស់ អៀង ធីរិទ្ធ E138/1/7/9, ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ២)។

[9] របាយការណ៍ប្រចាំឆមាសពីខែ តុលា ឆ្នាំ ២០១១ ដល់ខែ មេសា ឆ្នាំ ២០១២ ឯកសារលេខ E12/68/1.1 ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២ ទំព័រ ២។

[10] ការអនុវត្តអនុសាសន៍របស់អ្នកជំនាញទាក់ទងនឹងកម្មវិធីជំរុញបញ្ញាស្មារតី ៖ អៀង ធីរិទ្ធ ឯកសារលេខ E138/1/7/10 ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១២ ("អនុសាសន៍ស្តីពីកម្មវិធីលើកកម្ពស់សតិបញ្ញាស្មារតី") ទំព័រ ២។

ចលនាដែលបានឆ្លងកាត់ការបណ្តុះបណ្តាលនោះ គ្រូពេទ្យព្យាបាលដោយចលនាជនជាតិសិង្ហបុរី លោក Sudev SREEDHARAN ត្រូវបានតែងតាំងដើម្បីរៀបចំកម្មវិធីលម្អិតមួយដើម្បីលើកកម្ពស់បញ្ញាស្មារតីរបស់ជនជាប់ចោទ[11]។ នៅថ្ងៃទី ០៣ និងថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២ លោក SREEDHARAN បានផ្តល់ការបណ្តុះបណ្តាលដល់គ្រូពេទ្យព្យាបាលដោយចលនាសញ្ជាតិកម្ពុជាចំនួនពីររូប ដើម្បីពួកគាត់មានលទ្ធភាពអនុវត្តការព្យាបាលដោយចលនាសម្រាប់ជនជាប់ចោទ[12]។ គោលបំណងនៃការលើកកម្ពស់បញ្ញាស្មារតីនេះបានចាប់ផ្តើមកាលពីថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២ និងបានបញ្ចប់ទៅវិញ នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១២។

៦. បន្ទាប់ពីបានអនុវត្តតាមអនុសាសន៍ទាំងអស់ សម្រាប់ការព្យាបាលបន្ថែមតាមក្បួនវេជ្ជសាស្ត្រ អង្គជំនុំជម្រះបានស្នើសុំឱ្យអ្នកជំនាញវេជ្ជសាស្ត្រចំនួនទាំង០៥ រូប ដែលអង្គជំនុំជម្រះបានតែងតាំងដើម្បីវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដោយបានពន្យល់ថាជាការចាំបាច់ដែលត្រូវធ្វើការវាយតម្លៃនេះឱ្យបានឆាប់រហ័ស នៅពេលដែលវិធានការទាំងអស់ដែលអ្នកជំនាញបានណែនាំ ត្រូវបានសាកល្បងសម្រាប់រយៈពេលកំណត់នេះ[13]។ អ្នកជំនាញទាំងអស់ (សាស្ត្រាចារ្យ A. John Campbell, វេជ្ជបណ្ឌិត Seena FAZEL, និងវេជ្ជបណ្ឌិត ហួត លីនណា) ត្រូវបានស្នើសុំឱ្យធ្វើការវាយតម្លៃ អៀង ធីរិទ្ធ ឡើងវិញ នៅថ្ងៃទី ២៧ និងថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២ និងដាក់របាយការណ៍សង្ខេបរួម បន្ទាប់ពីពួកគាត់បានវាយតម្លៃឡើងវិញ ដើម្បីទុកលទ្ធភាពដល់ការធ្វើបទបង្ហាញ និងការពិភាក្សាតទល់អំពីលទ្ធផលដែលពួកគាត់បានរកឃើញនៅ ក្នុងសវនាការមួយដែលត្រូវបានធ្វើឡើងនៅថ្ងៃទី ៣០ និងថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២[14]។

៧. បន្ទាប់ពីមានការពិនិត្យមើលឡើងវិញអំពីព័ត៌មានវេជ្ជសាស្ត្រពាក់ព័ន្ធទាំងអស់ដែលមាន ចាប់តាំងពី

---

[11] អនុសាសន៍ស្តីពីកម្មវិធីលើកកម្ពស់សតិបញ្ញាស្មារតី ទំព័រ ២។

[12] របាយការណ៍នៃកម្មវិធីបណ្តុះបណ្តាលស្តីពីការលើកកម្ពស់សតិបញ្ញាស្មារតីដែលបានធ្វើនៅ អ.វ.ត.ក ពីថ្ងៃទី ០៣ ដល់ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២ ឯកសារលេខ E138/1/7/12 ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២ ("របាយការណ៍នៃកម្មវិធីបណ្តុះបណ្តាលស្តីពីការលើកកម្ពស់សតិបញ្ញាស្មារតី") (ជាអនុសាសន៍គួរធ្វើការព្យាបាលដោយចលនាប្រាំដងក្នុងមួយសប្តាហ៍ និងធ្វើការពិភាក្សាអំពីការរីកចម្រើននៅរៀងរាល់ពីរសប្តាហ៍រវាងសិក្ខាកាម និងអ្នកព្យាបាលដោយចលនា)។

[13] ការកំណត់ពេលវេលាដើម្បីវាយតម្លៃឡើងវិញ និងសវនាការលើបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ E138/1/7/13 ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១២ ("អនុស្សរណៈនៃការកំណត់ពេលវេលាសវនាការ"), ទំព័រ ២។

[14] អនុស្សរណៈនៃការកំណត់ពេលវេលាសវនាការ ទំព័រ ២។

ពេលមានការវាយតម្លៃឡើងវិញរបស់អង្គជំនុំជម្រះអំពីសម្បទាខាងបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ ដើម្បីចូលរួមសវនាការក្នុងខែ វិច្ឆិកា ឆ្នាំ ២០១១ ព្រមទាំងការសម្ភាសន៍បុគ្គលិកមន្ទីរឃុំឃាំង និងអ្នកមើលថែជនជាប់ចោទ អ្នកជំនាញទាំងនេះបានពិនិត្យជនជាប់ចោទ អៀង ធីរិទ្ធ កាលពីថ្ងៃទី ២៧ និងថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២។ អ្នកជំនាញទាំងនេះបានផ្តល់សេចក្តីសន្និដ្ឋានរបស់ពួកគាត់មកអង្គជំនុំជម្រះសាលាដំបូងនៅក្នុងរបាយការណ៍សង្ខេប ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ និងបានផ្តល់សក្ខីកម្មនៅថ្ងៃទី ៣០ និងថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២[15]។

## ៣. ការវាយតម្លៃមុនៗអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទដើម្បីចូលរួមការជំនុំជម្រះ និងសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ នៅពេលមានការវាយតម្លៃឡើងវិញ

៨. ចាប់តាំងពីពេលបានទទួលសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យមានការវាយតម្លៃដោយអ្នកជំនាញជាច្រើនទៅលើសុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់ អៀង ធីរិទ្ធ ដើម្បីបញ្ជាក់អំពីសម្បទារបស់គាត់ក្នុងការចូលរួមសវនាការ។ ការវាយតម្លៃនីមួយៗក្នុងចំណោមការវាយតម្លៃទាំងនេះ បានបង្ហាញអំពីការធ្លាក់ចុះបញ្ញាស្មារតីក្នុងកម្រិតគួរឲ្យកត់សម្គាល់[16]។ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃអំពីសម្បទាខាងបញ្ញាស្មារតីរបស់គាត់ ដើម្បីចូលរួមសវនាការនៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញអំពីការធ្វើវិនិច្ឆ័យដូចៗគ្នារបស់អ្នក ជំនាញទាំងប្រាំរូប ដែលអង្គជំនុំជម្រះបានតែងតាំង ដែលថា អៀង ធីរិទ្ធ កើតជំងឺវង្វេងស្មារតីក្នុងកម្រិតពីមធ្យមទៅធ្ងន់ធ្ងរដែលទំនងជាបណ្តាលមកពីជំងឺ Alzheimer និង

[15] របាយការណ៍សង្ខេបរបស់អ្នកជំនាញពាក់ព័ន្ធនឹង លោកស្រី អៀង ធីរិទ្ធ ឯកសារលេខ E138/1/7/13/2 ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ ("ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ"); ប្រតិចារឹក ថ្ងៃទី ៣០ ដល់ ៣១ ខែ សីហា ឆ្នាំ ២០១២។

[16] របាយការណ៍របស់អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ទាក់ទងនឹង អៀង ធីរិទ្ធ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ ឆ្លើយតបទៅនឹងដីការបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការចាត់តាំងជំនាញ ឯកសារលេខ E62/3, E62/3/6 ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១១ ("របាយការណ៍របស់អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់"); របាយការណ៍អ្នកជំនាញ រៀបចំឡើងដើម្បីឆ្លើយតបទៅនឹងដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E111 ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១ ឯកសារលេខ E111/8 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១១ ("របាយការណ៍អ្នកជំនាញផ្នែកចិត្តសាស្ត្រ"); របាយការណ៍ទាក់ទងនឹងលោកស្រី អៀង ធីរិទ្ធ ដាក់តាមសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១២ ("របាយការណ៍ស្តីពីអនុសាសន៍របស់អ្នកជំនាញ កថាខណ្ឌ ៧"), E138/1/7/4 ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ និងការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ។

បានសន្និដ្ឋានថា គាត់ពុំមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ដើម្បីចូលរួមសវនាការទេ[17]។ ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កាលពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ និងរបាយការណ៍បណ្តោះអាសន្នមួយចំនួនបង្ហាញច្បាស់ថាថ្វីបើមានការព្យាបាលបន្ថែមក្រោមការបង្គាប់របស់ អ.ជ.ត.ក ក៏ដោយ ក៏ការធ្លាក់ចុះផ្នែកបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ ពុំបានធូរស្រាលឡើយ ហើយបញ្ហានេះកាន់តែមានសភាព ធ្ងន់ធ្ងរចាប់តាំងពីគាត់ត្រូវបានអ្នកជំនាញវាយតម្លៃកាលពីក្នុងខែ កញ្ញា ឆ្នាំ ២០១១ ម្ល៉េះ[18]។

៩. នៅក្នុងរបាយការណ៍របស់ខ្លួនចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ អ្នកជំនាញនៅតែអះអាងអំពីលទ្ធផលនៃការធ្វើរោគវិនិច្ឆ័យថា ជនជាប់ចោទ អៀង ធីរិទ្ធ "ខូចប្រព័ន្ធប្រសាទក្នុងកម្រិតពីមធ្យមទៅធ្ងន់ធ្ងរ ដែលនៅមួយកម្រិតទៀតនឹងឈានទៅដល់ជំងឺបាត់បង់សមត្ថភាពផ្នែកបញ្ញាស្មារតី ហើយដែលទំនងបំផុតអាចជាជំងឺ Alzheimer"[19]។ ពួកគាត់បានកត់សម្គាល់ឃើញថា អៀង ធីរិទ្ធ ពុំបានចងចាំអំពីជំនួបមុនៗជាមួយពួកគាត់ឡើយ ហើយចម្លើយរបស់គាត់រមែងពុំពាក់ព័ន្ធនឹងសំណួរនោះទេ[20]។ គាត់ក៏ពុំអាចចាំលម្អិតអំពីគ្រួសាររបស់គាត់ ឬចំនួនកូនរបស់គាត់ផងដែរ។ គាត់បានពិន្ទុចំនួន ១២ លើ ៣០ លើវិធីសាស្ត្រមួយសម្រាប់ការវាយតម្លៃមុខងារបញ្ញាស្មារតីនោះគឺតេស្តវាយតម្លៃស្ថានភាពផ្លូវចិត្តខ្លីៗ MMSE[21] ។ អ្នកជំនាញបានពិចារណាឃើញថា ក្នុងការធ្វើតេស្តលើកនេះ មុខងារបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ មានសភាពយ៉ាប់យ៉ឺនជាងកាលពីពេលគាត់ធ្វើតេស្តលើកមុន ហើយរឿងរ៉ាវដែលអ្នកមើលថែរបស់គាត់បានប្រាប់ស៊ីសង្វាក់ជាមួយការវិវឌ្ឍន៍នៃជំងឺវង្វេងស្មារតីនេះ។ ពុំមានភស្តុតាងថា អៀង ធីរិទ្ធ បានធ្វើពុតដើម្បីបង្ហាញការធ្លាក់

---

17 សេចក្តីសម្រេចលើកទីមួយស្តីពីសម្បទាក្នុងការចូលរួមសវនាការ កថាខណ្ឌ ៥២ ដល់៥៩។

18 ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៦១; ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២, ទំព័រ ២៣, ២៩ និង ៤១។

19 របាយការណ៍ស្តីពីអនុសាសន៍របស់អ្នកជំនាញ កថាខណ្ឌ ៧។

20 របាយការណ៍ស្តីពីអនុសាសន៍របស់អ្នកជំនាញ កថាខណ្ឌ ៧។

21 របាយការណ៍ស្តីពីអនុសាសន៍របស់អ្នកជំនាញ កថាខណ្ឌ ៧។ ពីមុន អៀង ធីរិទ្ធ មានពិន្ទុ ១៤/៣០, ១៥/៣០ និង ១៨/៣០ លើតេស្តវាយតម្លៃស្ថានភាពផ្លូវចិត្តខ្លីៗ (MMSE) ក្នុងពេលពិន្ទុចំនួន ២៣/៣០ ឬតិចជាងនេះត្រូវបានចាត់ទុកជាសញ្ញាបញ្ជាក់ពីការចុះខ្សោយនៃដំណើរការខួរក្បាល (របាយការណ៍ជំនាញដែលត្រូវបានរៀបចំឡើងតាមដីកាជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E111 ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១ ឯកសារលេខ E111/8 ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១១ កថាខណ្ឌ ២១)។

00846941

ចុះសមត្ថភាពបញ្ញាស្មារតីឡើយ[22]។

១០. នៅក្នុងរបាយការណ៍ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១២ គ្រូពេទ្យព្យាបាលដោយចលនាបានកត់សម្គាល់ឃើញថា អៀង ធីរិទ្ធ "រីករាយស្វាគមន៍" ប៉ុន្តែគាត់ពុំអាចចាំអំពីចំនួនកូនរបស់គាត់ ឬឈ្មោះកូនរបស់គាត់ឡើយ[23]។ គាត់ក៏ពុំអាចចងចាំអំពីថ្ងៃ កាលបរិច្ឆេទ ឬឆ្នាំបានឡើយ[24]។ គ្រូពេទ្យព្យាបាលដោយចលនាបានរៀបចំតេស្ត MMSE និងបានកត់សម្គាល់ឃើញថា អៀង ធីរិទ្ធ បានពិន្ទុចំនួន ១២ លើ ៣០ នៅលើការវាយតម្លៃនេះ ប៉ុន្តែពុំអាចបន្តការវាយតម្លៃទៀតបានឡើយនៅថ្ងៃបន្ទាប់ដោយហេតុថា ជនជាប់ចោទកើតទុក្ខ និងតប់ប្រមល់[25]។

១១. នៅក្នុងរបាយការណ៍របស់អ្នកជំនាញដែលបានដាក់ជូនអង្គជំនុំជម្រះ កាលពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ បន្ទាប់ពីមានការវាយតម្លៃនាពេលថ្មីៗបំផុតទៅលើជនជាប់ចោទ អ្នកជំនាញវេជ្ជសាស្ត្រទាំងនេះបានសន្និដ្ឋានថា ជំងឺវង្វេងស្មារតីរបស់ អៀង ធីរិទ្ធ មានភាពកាន់តែធ្ងន់ធ្ងរ ចាប់តាំងពីឆ្នាំ ២០១១ ហើយសមត្ថភាពបញ្ញាស្មារតីរបស់គាត់ក៏បានធ្លាក់ចុះបន្តិចផងដែរ បើទោះបីជាមានការព្យាបាលដោយឱសថ Rivastigmine និងការព្យាបាលតាមរយៈការលើកកម្ពស់បញ្ញាស្មារតីក៏ដោយ[26]។ បន្ថែមពីលើភស្តុតាងដែលថា នាពេលបច្ចុប្បន្នគាត់មានអាការៈមមើមមាយ និងបត់ជើងតូចដោយពុំដឹងខ្លួននោះ[27] ការធ្លាក់ចុះនេះត្រូវបានបង្ហាញតាមរយៈការធ្លាក់ចុះពិន្ទុតេស្ត MMSE ដែលរៀបចំដោយបុគ្គលវិជ្ជាជីវៈ ដែលបានទទួលការបណ្តុះបណ្តាលផ្សេងៗគ្នា។ អ្នក

[22] របាយការណ៍ស្តីពីអនុសាសន៍របស់អ្នកជំនាញ កថាខណ្ឌ ៧។

[23] របាយការណ៍នៃកម្មវិធីបណ្តុះបណ្តាលស្តីពីការលើកកម្ពស់សតិបញ្ញាស្មារតី ទំព័រ ១។

[24] របាយការណ៍នៃកម្មវិធីបណ្តុះបណ្តាលស្តីពីការលើកកម្ពស់សតិបញ្ញាស្មារតី ទំព័រ ១។

[25] របាយការណ៍នៃកម្មវិធីបណ្តុះបណ្តាលស្តីពីការលើកកម្ពស់សតិបញ្ញាស្មារតី ទំព័រ ២ ("គាត់បានស្រែកឡើង ហើយមានអារម្មណ៍ថា មានសត្វល្អិតវារឡើងលើខ្លួនគាត់")។

[26] ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៦១។

[27] ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៤៣ ដល់ ៤៤ (ដោយធ្វើការកត់សម្គាល់លើរបាយការណ៍ដែលរៀបចំឡើងដោយប្រធានមន្ទីរឃុំឃាំង អ.វ.ត.ក និងបានបញ្ជាក់បន្ថែមដោយអ្នកឯកទេសព្យាបាលដោយចលនាថា អៀង ធីរិទ្ធ បានគិតថាមានមនុស្សបង្ហាញខ្លួននៅក្នុងមុងរបស់គាត់ និងថាពេលខ្លះ វត្ថុមាននោះគឺជាមនុស្ស និងពេលខ្លះទៀតគឺជាកុមារ ឬឆ្អឹងលលាដ៍ក្បាលមនុស្ស។ ប្រធានមន្ទីរឃុំឃាំង អ្នកយាមមន្ទីរឃុំឃាំងភេទស្រី និងអ្នកឯកទេសព្យាបាលដោយចលនា (ទាំងអស់ជាភេទស្រី) ក៏បានរាយការណ៍ថា លោកស្រី អៀង ធីរិទ្ធ នៅពេលថ្មីៗនេះ មិនអាចគ្រប់គ្រងការបត់ជើងតូច និងបត់ជើងតូចដោយមិនដឹងខ្លួន ហើយបានបដិសេធបញ្ហានេះនៅពេលសួរគាត់) និង កថាខណ្ឌ ៦១ (ដោយចាត់ទុកថាការវង្វេងរវាយថាជា "សញ្ញាមួយផ្សេងទៀតនៃការវិវត្តទៅមុខ"នៃជំងឺវង្វេងស្មារតី)។

ជំនាញបានរាយការណ៍ថា អៀង ធីរិទ្ធ កាលពីដំបូងបានពិន្ទុ ១៤, ១៥ និង ១៨ លើពិន្ទុ ៣០ នៅលើតេស្ត MMSE (ដែលរួមផ្សំជាមួយកត្តាផ្សេងៗ បង្ហាញអំពីការវង្វេងស្មារតីក្នុងកម្រិតពីមធ្យមទៅធ្ងន់ធ្ងរ)[28]។ បើទោះបីជាយ៉ាងណា នៅចន្លោះខែ ឧសភា ដល់ខែ សីហា ឆ្នាំ ២០១២ នៅក្នុងតេស្តដាច់ដោយឡែកពីគ្នា ដែលអ្នកជំនាញព្យាបាលដោយចលនាមួយរូប និងគ្រូពេទ្យព្យាបាលដោយចលនាចំនួន ០២ រូបបានរៀបចំឡើងនោះ ជនជាប់ចោទ អៀង ធីរិទ្ធ បានពិន្ទុចំនួន ១១-១៤ លើ ៣០[29]។ បន្ទាប់ពីការព្យាបាលបានបញ្ចប់ ជនជាប់ចោទបានពិន្ទុទាបជាងមុនក្នុងការធ្វើតេស្ត MMSE ដែលត្រូវបានរៀបចំដោយអ្នកជំនាញវេជ្ជសាស្ត្រ ពោលគឺបានធ្លាក់មកនៅត្រឹមពិន្ទុ ៧ និង ៩ តែប៉ុណ្ណោះ។ ពិន្ទុតិចជាង ១០ ជាពិន្ទុដែលបញ្ជាក់ថា មានការធ្លាក់ចុះធ្ងន់ធ្ងរ[30]។

១២. អ្នកជំនាញក៏បានសង្កេតឃើញទៀតអំពីការធ្លាក់ចុះការចងចាំ ដោយបានកត់សម្គាល់ថា គាត់ពុំបានចំណាំក្រុមការងារវាយតម្លៃ នៅពេលពួកគាត់មកពិនិត្យនៅថ្ងៃទី ២ ទេ ហើយគាត់ភ្លេចអ្វីដែលគាត់ទើបបាននិយាយកាលពីពេលប៉ុន្មាននាទីមុន[31]។ គាត់ក៏ពុំបានចាំថា ម្តាយរបស់គាត់ស្លាប់បាត់ទៅហើយ និងបានប្រកែកថា គាត់គ្មានកូន និងគាប់ជួនពេលខ្លះ គាត់ពុំស្គាល់ប្តីរបស់គាត់ឡើយ[32]។ ផ្អែកលើមូលដ្ឋាននេះ អ្នកជំនាញបានសន្និដ្ឋានថា ជំងឺវង្វេងស្មារតីរបស់ជនជាប់ចោទបានវិវឌ្ឍន៍ហើយ អៀង ធីរិទ្ធ នៅតែមិនអាចជួយប្រកបដោយអត្ថន័យ ក្នុងការរៀបចំការការពារខ្លួនរបស់គាត់ឡើយ ជាចម្បង គឺដោយសារតែការធ្លាក់ចុះការចងចាំរបស់គាត់[33]។ បន្ថែមពីលើការបញ្ជាក់ថា អៀង ធីរិទ្ធ បន្តកើតជំងឺវង្វេងស្មារតីក្នុងកម្រិតពីមធ្យមទៅធ្ងន់ធ្ងរ អ្នកជំនាញបានបញ្ជាក់ទៀតថា ពួកគាត់បានប្រើប្រាស់រួចហើយនូវរាល់គ្រប់មធ្យោបាយព្យាបាលទាំងអស់ដែលមាន ហើយនាពេលបច្ចុប្បន្នពុំមានការព្យាបាលណាមួយលើសពីនេះទៀត ដែលអាចធ្វើឱ្យបញ្ហាស្មារតីរបស់

[28] របាយការណ៍របស់អ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ កថាខណ្ឌ ២១។

[29] ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៤២ កថាខណ្ឌ ៦១ ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ២៣, ២៩, ៧៧ និង ៧៨។

[30] ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៤៨។

[31] ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៤៩ (នៅពេលរំឭកឡើងវិញ ជនជាប់ចោទបានច្រានចោលនូវអ្វីៗដែលគាត់បាននិយាយ)។

[32] ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៤៦ កថាខណ្ឌ ៥០។ អៀង សារី ដែលជាស្វាមីរបស់ជនជាប់ចោទ ក៏បានបញ្ជាក់ថា ការចងចាំរបស់អៀង ធីរិទ្ធ មានសភាពធុនដាបទៅ ក្នុងរយៈពេលមួយឆ្នាំចុងក្រោយនេះ (ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៤៥)។

[33] ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៥៣ កថាខណ្ឌ ៥៦ និងកថាខណ្ឌ ៦១។

00846943

ជនជាប់ចោទល្អប្រសើរឡើងឡើយ[34]។

១៣. នៅមុនមានសក្ខីកម្មរបស់អ្នកជំនាញតែបន្តិច គ្រូពេទ្យព្យាបាលមួយរូបរបស់ជនជាប់ចោទគឺ វេជ្ជបណ្ឌិត ចក ធីតា បានដាក់របាយការណ៍ដោយគ្មានការស្នើសុំជូនការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក ដោយបានសន្និដ្ឋានថា ជនជាប់ចោទពុំបានកើតជំងឺផ្លូវចិត្ត ឬការធ្លាក់ចុះសតិបញ្ញាស្មារតី ឡើយ[35]។ កាលពីថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានកោះហៅវេជ្ជបណ្ឌិត ចក ធីតា ឱ្យមកធ្វើជាសាក្សីដើម្បីអនុញ្ញាតឱ្យអង្គជំនុំជម្រះ និងអ្នកជំនាញសួរដេញដោលអំពីមូលដ្ឋាន នៃសេចក្តីសន្និដ្ឋានរបស់គាត់។

## ៤. សារណា

១៤. ដោយផ្អែកលើសេចក្តីសន្និដ្ឋាន និងសក្ខីកម្មរបស់អ្នកជំនាញ ភាគីទាំងអស់ លើកលែងតែសហ មេធាវីនាំមុខ ទទួលស្គាល់ថា ជនជាប់ចោទ អៀង ធីរិទ្ធ មានជំងឺវង្វេងស្មារតីដែលចេះតែវិវឌ្ឍន៍ ទៅមុខ (ដែលទំនងថាជាជំងឺ Alzheimer) និងថា គាត់នៅតែពុំមានសម្បទាខាងបញ្ញា ស្មារតីគ្រប់ គ្រាន់ដើម្បី ចូលរួមការជំនុំជម្រះបានទេ។ សហព្រះរាជអាជ្ញា និងមេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ ក៏បានយល់ស្របបន្ថែមទៀតថា ជនជាប់ចោទទំនងជាពុំមានសម្បទាខាង បញ្ញាស្មារតីគ្រប់ គ្រាន់ ដើម្បីចូលរួមការជំនុំជម្រះនាពេលខាងមុខ ហេតុនេះពុំមានលទ្ធភាពជាក់ស្តែងណាដែលថា គាត់នឹងត្រូវបានជំនុំជម្រះ នៅចំពោះមុខ អ.វ.ត.ក នោះទេ។ អាស្រ័យហេតុនេះ ភាគីទាំងពីរយល់

---

34 ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៥៩ ដល់ ៦០។

35 របាយការណ៍វេជ្ជសាស្ត្ររបស់ អៀង ធីរិទ្ធ ដែលរៀបចំឡើងដោយ ចក ធីតា ឯកសារ E12/78.1 ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១២ ; របាយការណ៍វេជ្ជសាស្ត្ររបស់ អៀង ធីរិទ្ធ ដែលរៀបចំឡើង ចក ធីតា ឯកសារលេខ E12/83.1 ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១២ (របាយការណ៍ដែលគ្មានចុះហត្ថលេខា ដែលបានផ្ញើតាមទូរសារ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២)។ បន្ទាប់ពីបានជួបជាមួយនឹង អៀង ធីរិទ្ធ នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ វេជ្ជបណ្ឌិត ចក ធីតា អះអាងថា បានត្រួតពិនិត្យ ជនជាប់ចោទ ម្តងក្នុងមួយខែ ហើយបានរៀបចំរបាយការណ៍វេជ្ជសាស្ត្រចំនួន ១១ (ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៣៨ និង៣៩)។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងបានទទួលរបាយការណ៍ចំនួន ០៦ ក្នុងចំណោម របាយការណ៍ទាំងនេះប៉ុណ្ណោះ (*មើល* ការពិនិត្យស្ថានភាពវិកលចរិត ឯកសារលេខ E17/1/2.4 ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១; របាយការណ៍ប្រចាំឆមាសពីខែ តុលា ឆ្នាំ ២០១១ ដល់ខែ មេសា ឆ្នាំ ២០១២ ឯកសារលេខ E12/68/1.1 ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២; របាយការណ៍វេជ្ជសាស្ត្រ របស់ អៀង ធីរិទ្ធ ឯកសារលេខ E138/1/7/4.3 ថ្ងៃទី ១៤ វិច្ឆិកា និង ០៩ ធ្នូ ឆ្នាំ ២០១១; របាយការណ៍វេជ្ជសាស្ត្ររបស់ អៀង ធីរិទ្ធ ដែលរៀបចំឡើងដោយ ចក ធីតា ឯកសារលេខ E12/78.1 ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១២; របាយការណ៍វេជ្ជសាស្ត្ររបស់ អៀង ធីរិទ្ធ ដែលរៀបចំឡើងដោយ ចក ធីតា ឯកសារ លេខ E12/83.1 ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១២)។

ស្របថា ជនជាប់ចោទគួរត្រូវបានដោះលែងពីមន្ទីរឃុំឃាំង អ.វ.ត.ក[36]។

១៥. ទោះបីបានដឹងថា ពុំមានមូលដ្ឋានណាផ្សេងទៀតសម្រាប់ការបន្តឃុំខ្លួនជនជាប់ចោទនោះក៏ដោយ ក៏សហព្រះរាជអាជ្ញាបានស្នើសុំលក្ខខណ្ឌ ០៦ ចំណុចសម្រាប់ការដោះលែងជនជាប់ចោទដែរ គឺថា ជនជាប់ចោទ៖

(១) ត្រូវស្នាក់នៅក្នុងអាសយដ្ឋានណាមួយច្បាស់លាស់។

(២) ត្រូវត្រៀមខ្លួនជានិច្ចដើម្បីឱ្យអាជ្ញាធរ ឬមន្ត្រីនានាដែលបានតែងតាំងដោយអង្គជំនុំជម្រះសាលាដំបូង ត្រួតពិនិត្យសុវត្ថិភាពជារៀងរាល់សប្តាហ៍។

(៣) ត្រូវប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណបណ្ណរបស់ខ្លួន។

(៤) មិនត្រូវទាក់ទងដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីជាមួយជនជាប់ចោទដទៃទៀតទេ (លើកលែងតែស្វាមីគាត់ គឺលោក អៀង សារី)។

(៥) មិនត្រូវទាក់ទងដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីជាមួយសាក្សី អ្នកជំនាញ ឬជនរងគ្រោះណាម្នាក់ ដែលភាគីបានស្នើឡើងដើម្បីផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងមិនត្រូវជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះទេ។

(៦) ត្រូវទទួលការពិនិត្យដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ដែលតែងតាំងដោយអង្គជំនុំជម្រះសាលាដំបូងរៀងរាល់ ០៦ ខែម្តង ដែលការពិនិត្យលើកដំបូងនឹងត្រូវធ្វើឡើងនៅខែ មីនា ឆ្នាំ ២០១៣។

១៦. សហព្រះរាជអាជ្ញាបានផ្តល់យោបល់ថា លក្ខខណ្ឌទាំងនេះអាចនឹងត្រូវពិចារណាសាជាថ្មីនៅចុងបញ្ចប់សំណុំរឿង ០០២/០២ ហេតុដូច្នេះ លក្ខខណ្ឌនេះមិនមែនជាវិធានការដែលដកហូតសិទ្ធិរបស់ជនជាប់ចោទពីការទទួលបានសេរីភាពជារៀងរហូតនោះទេ[37]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា គេគួរតែងតាំងអ្នកមើលថែទាំមួយរូបសម្រាប់ជនជាប់ចោទ អនុលោមតាមក្រមរដ្ឋប្បវេណីកម្ពុជា[38]។ ទោះបីបានដឹងថា ពុំមែនជាការងាយស្រួល ឬគ្មានលទ្ធភាពក្នុងការដាក់

---

[36] ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៩៩ ទំព័រ ១២៣ ដល់១២៤។

[37] ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ១១០ ដល់ ១១១។

[38] មូលដ្ឋាននៃការតែងតាំងឱ្យមានអ្នកអាណាព្យាបាល ឬហិតូបត្ថម្ភកៈសម្រាប់ជនដែលមានបញ្ហាស្មារតីធ្លាក់ចុះក្នុងប្រទេសកម្ពុជាមានរៀបរាប់នៅក្នុងផ្នែក ២៤ ដល់ ៣០ នៃក្រមរដ្ឋប្បវេណីកម្ពុជា។ ក្រមនេះមិនមែនជាផ្នែកមួយនៃយុត្តាធិការរបស់ អ.វ.ត.ក ក្រោមការកំណត់ក្របខណ្ឌច្បាប់របស់ខ្លួនឡើយ (*សូមមើល* ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០១ បូកជាមួយច្បាប់វិសោធនកម្ម ដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/

ទណ្ឌកម្ម ចំពោះការបំពានទៅលើលក្ខខណ្ឌទាំងនេះ ដោយសារស្ថានភាពបញ្ញាស្មារតីរបស់ជនជាប់ចោទក៏ដោយ ក៏សហព្រះរាជអាជ្ញាអះអាងថា ការបំពានលើលក្ខខណ្ឌទាំងនោះនឹងនាំឱ្យមានវិធានការនានា ដូចជាការព្រមានជាដើម (ដែលអាចជាការព្រមានចំពោះជនជាប់ចោទ ឬចំពោះអ្នកអាណាព្យាបាល)[39]។ មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ បានឆ្លើយតបវិញថា ដោយសារយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើជនជាប់ចោទនឹងត្រូវបញ្ចប់បន្ទាប់ពីមានការសម្រេចថា គាត់នឹងមិនត្រូវបានជំនុំជម្រះដោយ អ.វ.ត.ក ទៅហើយនោះ អង្គជំនុំជម្រះសាលាដំបូងលែងមានមូលដ្ឋានផ្លូវច្បាប់ដើម្បីដាក់លក្ខខណ្ឌចំពោះការដោះលែងរូបគាត់ទៀតហើយ[40]។

១៧. ដោយផ្អែកលើសេចក្តីសន្និដ្ឋានរបស់វេជ្ជបណ្ឌិត ចក ធីតា និងផ្ទុយពីគោលជំហររបស់សហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំឱ្យតែងតាំងក្រុមអ្នកជំនាញថ្មីផងដែរ។ សហមេធាវីនាំមុខបានអះអាងថា ក្រុមអ្នកជំនាញថ្មីគួរតែមានបញ្ចូលស្ត្រី និងអ្នកនិយាយភាសាខ្មែរ ដោយសំអាងថា អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ដែលតែងតាំងដោយអង្គជំនុំជម្រះសាលាដំបូងបានជួបនូវឧបសគ្គផ្នែកវប្បធម៌ និងភាសាជាមួយជនជាប់ចោទ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនបានបញ្ជាក់ថាតើ ឧបសគ្គផ្នែកវប្បធម៌ និងភាសា បានកើតឡើងយ៉ាងណាក្នុងការអនុវត្តជាក់ស្តែង ឬថាតើឧបសគ្គទាំងនេះបានធ្វើឱ្យបាត់បង់សុពលភាពនៃសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញដោយរបៀបណានោះទេ[41]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះកត់សម្គាល់ថា អ្នកជំនាញបរទេសបានដឹងពីភាពចាំបាច់ក្នុងការគិតគូរទៅដល់កត្តាវប្បធម៌ដែរ ឧទាហរណ៍ ដូចជាការស្វែងរកជំនួយពីមន្ត្រីបកប្រែជាភាសាខ្មែរ វេជ្ជបណ្ឌិតខ្មែរ និងគិលានុប្បដ្ឋាក គិលានុប្បដ្ឋាយិកាជនជាតិខ្មែរ។ អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ (ដែលម្នាក់ក្នុងចំណោមនោះជាគ្រូពេទ្យផ្នែកវិកលចរិតជាជនជាតិខ្មែរ) ក៏បានពឹងផ្អែកលើប្រវត្តិព័ត៌មានយ៉ាងទូលំទូលាយពីជនជាតិខ្មែរ ដែលបានចូលរួមថែទាំលោកស្រី អៀង ធីរិទ្ធ រៀងរាល់ថ្ងៃ រួមមាន បុគ្គលិកសន្តិសុខជាស្ត្រី

---

១០០៤/ ០០៦), មាត្រា ២ ថ្មី មាត្រា ៣ ថ្មី មាត្រា ៤ ដល់ ៨ និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានចុះហត្ថលេខា នៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ និងបានចូលជាធរមាន នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥, មាត្រា ៩ (ការកំណត់យុត្តាធិការរបស់ អ.វ.ត.ក)។

[39] ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ១១៣ ដល់ ១១៥។

[40] ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ១២៨ ដល់ ១២៩។

[41] ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ១២២ ដល់ ១២៣។

គ្រូពេទ្យព្យាបាលដោយចលនា និងប្រធានមន្ទីរឃុំឃាំង[42]។ ហេតុនេះ អង្គជំនុំជម្រះពិចារណាថា អ្នកជំនាញផ្នែកវេជ្ជសាស្ត្របានគិតគូរទៅដល់ភាពខុសគ្នាផ្នែកវប្បធម៌ និងភាសា ក្នុងការបំពេញកិច្ចការពិនិត្យផ្នែកវេជ្ជសាស្ត្ររបស់ខ្លួន។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបដិសេធសំណើរបស់សហមេធាវីនាំមុខ។

## ៥. ច្បាប់ជាធរមាន

១៨. បទដ្ឋានដើម្បីសម្រេចថាតើជនជាប់ចោទមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ ដើម្បីចូលរួមការជំនុំជម្រះ ត្រូវបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងថាជាការចូលរួមប្រកបដោយអត្ថន័យខ្លឹមសារ ដែលអនុញ្ញាតឱ្យជនជាប់ចោទអនុវត្តសិទ្ធិ ដែលទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ក្នុងកម្រិតមួយដែលគាត់អាចចូលរួមយ៉ាងមានប្រសិទ្ធភាព និងបានយល់ពីសារប្រយោជន៍នៃកិច្ចដំណើរការនីតិវិធី[43]។ បទដ្ឋាននេះមិនត្រូវបានប្តឹងសាទុក្ខ ឬបដិសេធដោយ អ.ជ.ត.ក ឡើយ។ ការវិភាគរបស់អង្គជំនុំជម្រះតុលាការកំពូលគឺពាក់ព័ន្ធជាសំខាន់លើបញ្ហាថា តើការដោះលែងជនជាប់ចោទដោយអង្គជំនុំជម្រះសាលាដំបូងជាការសមស្រប ឬយ៉ាងណាបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា គាត់ពុំមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ដើម្បីចូលរួមការជំនុំជម្រះ។

១៩. ពាក់ព័ន្ធនឹងបញ្ហានៃការដោះលែង ចៅក្រមភាគច្រើននៅអង្គជំនុំជម្រះតុលាការកំពូលបានសំអាងដោយផ្អែកទៅលើក្របខ័ណ្ឌនីតិវិធី ដែលមានក្នុងកថាខណ្ឌ ៣៦ និង ៣៧ នៃសេចក្តីសម្រេចរបស់

[42] ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ១២២ ដល់ ១២៣។

[43] សេចក្តីសម្រេចលើកទីមួយស្តីពីសម្បទាក្នុងការចូលរួមសវនាការ កថាខណ្ឌ ២៧ *ដកស្រង់ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Strugar*, សាលដីកា, អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-01-42-A) ថ្ងៃទី ១៧ កក្កដា ឆ្នាំ ២០០៨ ("សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនៃរឿងក្តី *Strugar*"), កថាខណ្ឌ ៥៥; *មើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Pavle Strugar*, សេចក្តីសម្រេចទាក់ទងនឹងញត្តិរបស់មេធាវីការពារក្តីក្នុងការស្នើសុំបញ្ឈប់កិច្ចដំណើរការនីតិវិធី, អង្គជំនុំជម្រះសាលាដំបូង ICTY, សំណុំរឿង លេខ IT-01-42-T ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៤ ("សេចក្តីសម្រេចលើសម្បទា ក្នុងរឿងក្តី *Strugar*"), កថាខណ្ឌ ៣៥; *អគ្គរដ្ឋអាជ្ញារងទទួលបន្ទុកឧក្រិដ្ឋកម្មធ្ងន់ធ្ងរ តទល់នឹង Josep Nahak*, សំអាងហេតុ និងដីកាស្តីពីសមត្ថភាពរបស់ជនជាប់ចោទ *Nahak* ក្នុងការចូលរួមសវនាការ, គណៈកម្មាធិការពិសេសទទួលបន្ទុកឧក្រិដ្ឋកម្មធ្ងន់ធ្ងរ (ទីម័រខាងកើត), សំណុំរឿង លេខ *01A/2004*, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៥ ("សេចក្តីសម្រេចលើរឿងក្តី *Nahak*"), កថាខណ្ឌ ៥៦។

តុលាការ ICC លើរឿងក្តី *Lubanga*[44]។ នីតិវិធីក្នុងរឿងក្តីនោះត្រូវបានផ្អាក ដោយសារ រដ្ឋអាជ្ញាខកខានមិនបានបញ្ចេញឱ្យដឹងនូវចំណុចសំខាន់នៃភស្តុតាងដោះបន្ទុកដល់ជនជាប់ចោទ និងមិនស្របទៅនឹងការចោទប្រកាន់ស្តីពីភាពពុំមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ដើម្បីចូលរួមការជំនុំជម្រះ[45]។ នៅក្នុងការវាយតម្លៃថាតើជនជាប់ចោទគួរតែត្រូវឃុំខ្លួន ឬដោះលែង បន្ទាប់ពីរដ្ឋអាជ្ញាបានបំពានលើកាតព្វកិច្ចនៃការចូលរួមសវនាការប្រកបដោយយុត្តិធម៌នោះ (ហើយបញ្ជាក់លទ្ធភាពដែលថា ការរំលោភបំពានបែបនេះអាចនឹងមានត្រូវជួសជុលវិញ និងការជំនុំជម្រះត្រូវបានបន្ត) តុលាការ ICC បានលើកឡើងថា៖

> ៣៦. ការពិតគឺថា ការឃុំខ្លួនតាមមាត្រា ៦០ និង ៥៨(១) នៃលក្ខន្តិកៈ [តុលាការ ICC] ត្រូវតែពាក់ព័ន្ធទៅនឹងការអនុវត្តយុត្តាធិការ ផ្នែកព្រហ្មទណ្ឌទៅលើបុគ្គលដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើសក្រោមយុត្តាធិការរបស់តុលាការ។ ហេតុនេះ នៅក្នុងព្រឹត្តិការណ៍ធម្មតា ប្រសិនបើតុលាការសម្រេចផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ និងមិនអាចប្រែប្រួលនោះ ជនជាប់ចោទនឹងត្រូវបានដោះលែង ដោយសារការបន្តឃុំខ្លួននឹងពុំមានទំនាក់ទំនងជាមួយការអនុវត្តយុត្តាធិការព្រហ្មទណ្ឌដោយតុលាការទេ។

---

44 *Lubanga*, ICC-01/04-01/06-1487, "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទីមួយ ដែលមានចំណងជើងថា 'សេចក្តីសម្រេចលើការដោះលែងនៅក្រៅឃុំរបស់ Thomas Lubanga Dyilo" អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៨ ("សេចក្តីសម្រេចឃុំខ្លួន *Lubanga*")។

45 *Lubanga,* ICC-01/04-01/06-1487, សេចក្តីសម្រេចអំពីផលវិបាកនៃការមិនផ្សព្វផ្សាយភស្តុតាងដោះបន្ទុក ដែលមានចែងក្នុងមាត្រា ៥៤(៣)(ង) នៃកិច្ចព្រមព្រៀង និងពាក្យសុំផ្អាកការជំនុំជម្រះជនជាប់ចោទ រួមទាំងបញ្ហាផ្សេងៗទៀតដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ ដែលបានធ្វើឡើងនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៨ អង្គជំនុំជម្រះសាលាឧទ្ធរណ៍តុលាការ ICC, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៨, កថាខណ្ឌ ៩៣ ដល់៩៤ (អង្គជំនុំជម្រះសម្រេចថា វាជាការចាំបាច់ក្នុងការលុបចោលការសុំផ្អាកកិច្ចដំណើរការនីតិវិធី ពីព្រោះថា ប្រសិនបើរដ្ឋអាជ្ញាមានការបំពានកាតព្វកិច្ចរបស់ខ្លួននោះ ការជំនុំជម្រះក្នុងដំណាក់កាលនោះ "មិនអាចចាត់ទុកជាការជំនុំជម្រះក្តីដោយយុត្តិធម៌ឡើយ")។ ជាចុងក្រោយ ការជំនុំជម្រះជនជាប់ចោទនេះត្រូវបានបន្តធ្វើឡើងវិញ ហើយការចេញសាលក្រមប្រឆាំងនឹងរូបគាត់ត្រូវបានធ្វើឡើង នៅថ្ងៃទី ១៤ មីនា ឆ្នាំ ២០១២ (*Lubanga*, ICC-01/04-01/06-1487, សាលក្រមអនុលោមមាត្រា៧៤ នៃលក្ខន្តិកៈ អង្គជំនុំជម្រះសាលាដំបូង ICC កថាខណ្ឌ ១០; *សូមមើលផងដែរ, Lubanga*, ICC-01/04-01/06-2690, សេចក្តីសម្រេចលើ "ការស្នើសុំរបស់មេធាវីការពារក្តីសុំការផ្អាកជាអចិន្ត្រៃយ៍នូវកិច្ចដំណើរការនីតិវិធី", អង្គជំនុំជម្រះសាលាដំបូង ICC ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១ (ដោយមានកោសលុប), កថាខណ្ឌ ១៩៥ កថាខណ្ឌ ១៩៩ កថាខណ្ឌ ២០៥ (ដោយគត់សម្គាល់ឃើញថា កំហុសឆ្គងវិជ្ជាជីវៈរបស់រដ្ឋអាជ្ញាមិនតែងតែតម្រូវឱ្យមានការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ឡើយ ពីព្រោះកំហុសឆ្គងនោះអាចធ្វើការដោះស្រាយក្នុងអំឡុងពេលជំនុំជម្រះ)។

៣៧. ទោះជាយ៉ាងណាក្តី បញ្ហានេះ ជាបញ្ហាខុសគ្នា នៅពេលដែលកិច្ចដំណើរការនីតិវិធីត្រូវបានផ្អាក ដោយមានលក្ខខណ្ឌ ដូចក្នុងរឿងក្តីនេះ។ ការផ្អាកដោយមានលក្ខខណ្ឌពុំមែនជាការលើកលែងការចោទប្រកាន់ ឬជាការបញ្ចប់ជាស្ថាពរនូវកិច្ចដំណើរការនីតិវិធីទេ តែអាចនឹងត្រូវបញ្ចប់បានក្នុងកាលៈទេសៈសមស្រប [...]។ ហេតុនេះ តុលាការមិនត្រូវបានរារាំងជាអចិន្ត្រៃយ៍មិនឲ្យអនុវត្តយុត្តាធិការទៅលើបុគ្គលដែលពាក់ព័ន្ធនោះទេ។ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ចំណុចនេះយ៉ាងច្បាស់ក្នុងការអះអាងថា ការផ្អាកដែលអង្គជំនុំជម្រះបានដាក់អាចនឹងត្រូវបញ្ចប់វិញបាននាពេលអនាគត [...]។ សម្រាប់សំអាងហេតុនោះ នៅពេលដែលអង្គជំនុំជម្រះបានបង្គាប់ឲ្យផ្អាកកិច្ចដំណើរការនីតិវិធីដោយមានលក្ខខណ្ឌនោះ ជម្រើសមិនមែនមានតែការដោះលែងដោយគ្មានលក្ខខណ្ឌចំពោះបុគ្គលដែលពាក់ព័ន្ធនោះទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះនឹងត្រូវតែពិចារណាដល់កាលៈទេសៈពាក់ព័ន្ធទាំងអស់ និងសម្រេចថាតើគួរដោះលែង ឬបន្តឃុំខ្លួន ដោយផ្អែកលើលក្ខខណ្ឌនានាក្នុងមាត្រា ៦០ និង ៥៨(១) នៃលក្ខន្តិកៈ [តុលាការ ICC]។ ជាពិសេស ភាពចាំបាច់នៃការបន្តឃុំខ្លួន [...] នឹងត្រូវតែវាយតម្លៃយ៉ាងយ៉ាងប្រុងប្រយ័ត្ន។ [...] អង្គជំនុំជម្រះគួរពិចារណាថា សវនាការត្រូវបានផ្អាកដោយមានលក្ខខណ្ឌ ពុំមែនជាការបញ្ចប់ជាអចិន្ត្រៃយ៍នោះទេ។ ប្រសិនបើស្របនឹងលក្ខខណ្ឌនៃការបន្តឃុំខ្លួន អង្គជំនុំជម្រះនឹងត្រូវសម្រេចថា តើក្នុងកាលៈទេសៈពិសេសនៃរឿងក្តីនោះ ការដោះលែងគួរតែមាន ឬគ្មានលក្ខខណ្ឌ [...]។ *នៅពេលសម្រេចលើការឃុំខ្លួន ឬដោះលែងនោះ (ដោយមាន ឬគ្មានលក្ខខណ្ឌ) អង្គជំនុំជម្រះនឹងត្រូវតែពិចារណា [...] អំពីការវិវឌ្ឍន៍បន្ថែមទៀត ពីព្រោះការសម្រេចផ្អាកដោយមានលក្ខខណ្ឌ អាចនឹងមានលទ្ធភាពថា ការផ្អាកអាចនឹងត្រូវបានបញ្ចប់ទៅវិញក្នុងពេលអនាគតដ៏ខ្លីខាងមុខ។* ស្របពេលជាមួយគ្នានោះ អង្គជំនុំជម្រះត្រូវតែប្រុងប្រយ័ត្នថា ការបន្តឃុំខ្លួននឹងមិនត្រូវធ្វើឡើងក្នុងរយៈពេលយូរដោយមិនសមហេតុសមផលនោះទេ ព្រោះវាជាការបំពានដល់សិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។ ប្រសិនបើអង្គជំនុំជម្រះសន្និដ្ឋានថា មានយុត្តិកម្មសម្រាប់ការបន្តឃុំខ្លួន ឬការដោះលែងត្រូវមានលក្ខខណ្ឌនោះ អង្គជំនុំជម្រះក៏នឹងត្រូវពិនិត្យឡើងវិញនូវសេចក្តីសម្រេចនោះក្នុងពេលដ៏ខ្លីដែរ[46]។

[46] សេចក្តីសម្រេចឃុំ*ខ្លួន* *Lubanga* កថាខណ្ឌ ៣៦ ដល់ ៣៧ (បញ្ជាក់បន្ថែម)។ ផ្នែកដែលមានអក្សរទ្រេតនៃកថាខណ្ឌ ៣៧ ក្នុងសេចក្តីសម្រេចរឿងក្តី *Lubanga* ត្រូវបានកោសលុប ពេលមានការដកស្រង់កថាខណ្ឌនេះពីសំណាក់អង្គជំនុំជម្រះ

00846949

២០. ដោយសំអាងលើមូលដ្ឋាននេះ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានដោយសំឡេងភាគច្រើនថា "មុនពេលដោះលែងជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងគួរតែបានវាយតម្លៃរាល់អត្ថប្រយោជន៍ និងថ្លឹងថ្លែងឲ្យបានត្រឹមត្រូវរាល់កត្តាពាក់ព័ន្ធជាមុន"[47]។ សេចក្ដីសម្រេចដោយសំឡេងភាគច្រើនរបស់អង្គជំនុំជម្រះតុលាការកំពូលក៏បានកត់សម្គាល់បន្ថែមទៀតថា "ទោះបីអង្គជំនុំជម្រះសាលាដំបូងមិនបានកំណត់បទដ្ឋាននៃភស្តុតាង ដែលខ្លួនប្រើប្រាស់ក្នុងការវាយតម្លៃលើក្ដីសង្ឃឹម ដែលធ្វើឲ្យស្ថានភាពរបស់ជនជាប់ចោទបានប្រសើរឡើងក៏ដោយ ក៏បទដ្ឋាននេះទំនងជាមានលក្ខណៈខ្ពស់ពេកសម្រាប់គោលបំណងនៃការពិចារណាជាពិសេសនេះ [*ពោលគឺ* តើជនជាប់ចោទគួរត្រូវបានដោះលែង ឬយ៉ាងណា]"[48]។

២១. ពាក់ព័ន្ធនឹងបទដ្ឋាននេះ តុលាការកំពូលសហរដ្ឋអាមេរិកក្នុងសំណុំរឿង *Jackson ទល់នឹង Indiana* (ដែលត្រូវបាន អ.ជ.ត.ក លើកយកមកសំអាង) បានសម្រេចថា ប្រសិនបើពុំមានលទ្ធភាពខ្ពស់ដែលថា ជនជាប់ចោទនឹងមានសមត្ថភាពដើម្បីចូលរួមសវនាការក្នុងពេលដែលអាចប្រមើលឃើញនាពេលខាងមុខទេនោះ ជនជាប់ចោទត្រូវតែទទួលបានការដោះលែង[49]។ ប្រព័ន្ធច្បាប់ជាតិផ្សេងៗក៏បានកំណត់ថា ការឃុំខ្លួនដែលគ្មានរយៈពេលជាក់លាក់ ឬសូម្បីតែការឃុំខ្លួនដោយមានការពិនិត្យមើលឡើងវិញជាប្រក្រតីក៏ដោយ ក៏ផ្ទុយទៅនឹងសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ

---

តុលាការកំពូល។

[47] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្ដឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៣០។

[48] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្ដឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ២៩។

[49] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្ដឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ២៥, ជើងទំព័រ ៨៤ *ដកស្រង់ពី រឿងក្ដី Jackson ទល់នឹង Indiana*, 406 U.S. 715, 738 (១៩៧២) ៖ "ជនម្នាក់ដែលត្រូវបានរដ្ឋចោទប្រកាន់ពីបទល្មើសឧក្រិដ្ឋ ហើយត្រូវបានសម្រេចបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យដោយផ្អែកទៅលើមូលដ្ឋានតែមួយគត់គឺការគ្មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី នឹងមិនត្រូវបានឃុំខ្លួនឲ្យលើសពីរយៈពេលដែលសមស្របសម្រាប់ការសម្រេច ថាតើនឹងមានលទ្ធភាពច្បាស់លាស់ដែរឬទេថាជននោះនឹងទទួលបាននូវសម្បទាគ្រប់គ្រាន់ឡើងវិញនៅក្នុងពេលវេលាជាក់លាក់នាថ្ងៃខាងមុខ។ ក្នុងករណីដែលមានការសម្រេចថាជននោះនឹងមិនមានលទ្ធភាពបែបនេះទេ រដ្ឋចាំបាច់ត្រូវតែអនុវត្តដំណើរការនីតិវិធីជាទំនៀមទម្លាប់ក្នុងការបញ្ជូនជននោះទៅព្យាបាលនៅមន្ទីរពេទ្យដែលតម្រូវឲ្យធ្វើការព្យាបាលដោយគ្មានពេលកំណត់ចំពោះជនគ្រប់រូប ឬក៏រដ្ឋចាំបាច់ត្រូវតែធ្វើការដោះលែងជនជាប់ចោទ។ លើសពីនេះទៅទៀត បើទោះបីជាមានការសម្រេចថា ជនជាប់ចោទអាចមានលទ្ធភាពទទួលបានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការក្នុងពេលឆាប់ៗខាងមុខក៏ដោយ ក៏ការព្យាបាលជំងឺចំពោះជននេះត្រូវតែបន្តធ្វើដោយផ្អែកលើយុត្តិកម្មនៃការវិវឌ្ឍន៍ដើម្បីឈានទៅរកគោលដៅនៃការទទួលបានសម្បទាគ្រប់គ្រាន់របស់ជនជាប់ចោទ។

ដែរ[50]។ ជាឧទាហរណ៍ តុលាការសហព័ន្ធអូស្ត្រាលីបានវាយតម្លៃអំពីភាពស្របច្បាប់នៃការឃុំខ្លួនចុងចោទ ដែលពុំមានលទ្ធភាពជាក់ស្តែងនៃការមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ដើម្បីចូលរួមការជំនុំជម្រះ។ ដោយបានបដិសេធដីកាបង្គាប់ឱ្យឃុំខ្លួន ដោយមានការពិនិត្យមើលឡើងវិញរៀងរាល់រយៈពេល ០៦ ខែ តុលាការនេះបានសម្រេចថា៖

> រាល់ការលើកឡើងណាមួយដែលថា បុគ្គលណាម្នាក់ អាចត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងរយៈពេលជាច្រើនឆ្នាំដោយពុំមានការជំនុំជម្រះ ឬលទ្ធភាពនៃការជំនុំជម្រះ ត្រឹមតែហេតុផលថាមានការចោទប្រកាន់ប្រឆាំងនឹងបុគ្គលនោះ ដែលបុគ្គលនោះនឹងពុំអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីឆ្លើយតបនឹងបទចោទ គឺផ្ទុយស្រឡះទៅនឹងការគាំពារសិទ្ធិក្នុងការទទួលបានសេរីភាពក្នុងប្រព័ន្ធច្បាប់របស់យើង។ ការកំរិតសិទ្ធិណាមួយនឹងទាមទារឱ្យមានភស្តុតាងច្បាស់លាស់អំពីចេតនារបស់អង្គនីតិបញ្ញត្តិមុនពេលការធ្វើបែបនេះអាចត្រូវបានអនុញ្ញាត[51]។

២២. ដូចដែល អ.ជ.ត.ក បានកត់សម្គាល់ ប្រព័ន្ធច្បាប់កម្ពុជាក៏ការពារសិទ្ធិក្នុងការទទួលបានសេរីភាពផងដែរ និងមានការសន្មតមួយដែលគាំទ្រការដោះលែងជនជាប់ចោទដែលរង់ចាំការជំនុំជម្រះ[52]។ លក្ខខណ្ឌតម្រូវជាសារវ័ន្តមួយនៃនិយាមសិទ្ធិមនុស្សអន្តរជាតិក៏ចែងថា ការដកហូតសេរីភាពត្រូវតែមានសំអាងហេតុដែលមានមូលដ្ឋានត្រឹមត្រូវតាមច្បាប់[53]។ ត្រង់ប្រការនេះ តុលាការសិទ្ធិមនុស្សអឺរ៉ុប ("ECtHR") បានសម្រេចថា សំអាងហេតុសម្រាប់ការឃុំខ្លួនមុនពេលមានការជំនុំជម្រះ អាចប្រែក្លាយជាពុំសូវមានទម្ងន់ទៅតាមពេលវេលា ហើយក្នុងកាលៈទេសៈបែបនេះ បុគ្គល

---

50 *សូមមើល R តទល់នឹង Jabanardi* (១៩៨៣) 50 ALR, 147; *សូមមើលផងដែរ ក្រមព្រហ្មទណ្ឌ*, R.S.C., ១៩៨៥, c. C-46, ss. 672.54, 672.55(1), 672.58 (កាណាដា) (អនុញ្ញាតតុលាការឱ្យស្នើការព្យាបាលជនជាប់ចោទ ក្នុងរយៈពេលជាក់លាក់មួយមិនលើសពី ៦០ ថ្ងៃ ក្នុងគោលបំណងឱ្យជនជាប់ចោទអាចចូលរួមក្នុងសវនាការ ហើយបន្ទាប់ពីរយៈពេលនេះ ការព្យាបាលផ្នែកចិត្តសាស្ត្រអាចអនុញ្ញាតឱ្យបន្តធ្វើបានលុះត្រាមានការយល់ព្រមពីជនជាប់ចោទ ហើយការព្យាបាលដូចនេះមានមូលហេតុថាជាការព្យាបាលចាំបាច់ និងជាប្រយោជន៍របស់ជនជាប់ចោទ); ច្បាប់សុខភាពផ្លូវចិត្ត ឆ្នាំ ១៩៨៣, ss. 36(1), 37 (ចក្រភពអង់គ្លេស) (ដោយអនុញ្ញាតឱ្យបញ្ជូនជនជាប់ចោទទៅកាន់មន្ទីរពេទ្យដើម្បីព្យាបាលរហូតដល់រយៈពេល ១២ សប្តាហ៍ ក្នុងករណីជនជាប់ចោទមានជំងឺផ្លូវចិត្តដែលធ្វើឱ្យការដាក់ឃុំនៅក្នុងមន្ទីរពេទ្យដើម្បីព្យាបាលវេជ្ជសាស្ត្រគឺជាការសមស្រប ហើយការព្យាបាលវេជ្ជសាស្ត្រសមស្របនេះពិតជាអាចរកបាន)។

51 *R តទល់នឹង Jabanardi*, 50 ALR 147 at 151-52 (ដកស្រង់ *ក្នុងរឿងក្តី Jackson តទល់នឹង Indiana*)។

52 សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៣៩; *សូមមើលផងដែរ* វិធាន ៦៣(៣), វិធាន ៨២(១) នៃវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២០៥ និងមាត្រា ៣០៦។

53 អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មាត្រា ៥ *សូមមើលផងដែរ* កតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៩; អនុសញ្ញាសហរដ្ឋអាមេរិកស្តីពីសិទ្ធិមនុស្ស មាត្រា ៧ និងធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិមនុស្ស មាត្រា ៦។

00846951

ពាក់ព័ន្ធគួរត្រូវបានដោះលែង[54]។ តុលាការខាងលើបានសម្រេចថា ទម្ងន់នៃការចោទប្រកាន់ ប្រតិកម្មជាសាធារណៈទៅនឹងការចោទប្រកាន់ និងភាពធ្ងន់ធ្ងរនៃការផ្តន្ទាទោសដែលអាចមាន អាចត្រូវបានយកទៅពិចារណាក្នុងការសម្រេចឃុំខ្លួនជនជាប់ចោទ ប៉ុន្តែសំអាងហេតុទាំងនេះពុំ អាចមានយុត្តិកម្មសម្រាប់ការឃុំឃាំងរយៈពេលយូរអង្វែងបានឡើយ[55]។ លើសពីនេះទៀត យុត្តិកម្មសម្រាប់ការឃុំខ្លួនបន្ត ត្រូវតែថ្លឹងថ្លែងជាមួយនឹងហានិភ័យនៃការដកហូតសេរីភាពដោយ គ្មានការកំណត់ពេល ឬមានរយៈពេលយូរអង្វែងហួសហេតុ[56]។

---

54 *Letellier តទល់នឹង France*, សាលក្រម, ECtHR (លេខ 12369/86) ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩១ កថាខណ្ឌ ៣៩។

55 *Khudoyorov តទល់នឹង Russia*, សាលក្រម, ECtHR (លេខ 6847/02) ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៥, កថាខណ្ឌ ១៨០; *Letellier តទល់នឹង France*, សាលក្រម, ECtHR (លេខ 12369/86) ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩១ កថាខណ្ឌ ៥១។

56 សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ២៤។ តុលាការសិទ្ធិមនុស្សអន្តរជាតិ បានសម្រេចជាឯកច្ឆន្ទថា ការដាក់ឃុំឃាំងមុនពេលសវនាការរយៈពេលយូរ ដោយគ្មានហេតុផល គឺជាការរំលោភដល់សិទ្ធិ ជាសារវន្តរបស់ជនជាប់ចោទ ដោយរួមទាំងក្នុងករណីខ្លះពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ឬឧក្រិដ្ឋកម្មដែលមានលក្ខណៈ ស្មុគស្មាញជាពិសេសផង; *សូមមើល ឧទាហរណ៍ រឿងក្តី* Labita *តទល់នឹង* Italy, សាលក្រម, អង្គជំនុំជម្រះធំ, តុលាការសិទ្ធិមនុស្សអឺរ៉ុប (លេខ 26772/95) ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០០០ កថាខណ្ឌ ១៥៤ កថាខណ្ឌ ១៦១ កថាខណ្ឌ ១៦៤ (ការឃុំខ្លួនបណ្តោះអាសន្នរយៈពេល ២ ឆ្នាំ និង ៧ ខែ នៅក្នុងករណីមួយ ទាក់ទងនឹងសមាជិកនៃអង្គការឧក្រិដ្ឋជន (Mafia) ដែលរងការចោទប្រកាន់ចំនួន ៤៦ ដែលនេះគឺជារយៈពេលយូរដោយគ្មានហេតុផល); *Soria Valderrama តទល់នឹង France*, សាលក្រម, ECtHR (លេខ 29101/09), ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២, កថាខណ្ឌ ៣០ (យល់ឃើញថា ការឃុំខ្លួនចំនួន ៤ ឆ្នាំ និង៨ ខែ គឺជាការមិនសមហេតុផល*តាមការវិភាគបឋម* ហើយចាំបាច់ត្រូវមានការ បកស្រាយដោយផ្អែកលើជាពិសេសហេតុផលច្បាស់លាស់); *Piechowicz តទល់នឹង* Poland, *សាលក្រម*, ECtHR (លេខ 20071/07), ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២, កថាខណ្ឌ ១៨៨ កថាខណ្ឌ ១៩៧; *Todorov តទល់នឹង Ukraine, សាលក្រម*, ECtHR (លេខ 16717/05), ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២, កថាខណ្ឌ ៦១ ដល់ ៦៤; *សំណុំរឿង Suárez-Rosero តទល់នឹង Ecuador*, សាលសក្រម, I/A Court H.R., ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧, (អង្គសេចក្តី), កថាខណ្ឌ ៧៣ (ការឃុំខ្លួនបណ្តោះអាសន្នរយៈពេលបួនឆ្នាំ" ត្រូវបានធ្វើឡើងហួសពីរយៈពេលសមស្របដែលមានចែងនៅក្នុង អនុសញ្ញាសហរដ្ឋអាមេរិក"); *Anthony Briggs Trinidad និង Tobago,* របាយការណ៍របស់គណៈកម្មាធិការអន្តរ អាមេរិកស្តីពីសិទ្ធិមនុស្ស ៤៤/៩៩ (សំណុំរឿង 11.815), ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥៥។ បើទោះបីជារយៈពេលឃុំខ្លួនមុនសវនាការចំពោះមុខតុលាការអន្តរជាតិមិនអចិន្ត្រៃយ៍មានរយៈពេលជាទូទៅយូរក៏ដោយ ក៏ករណីទាំងអស់ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងជនជាប់ចោទដែលកំពុងទទួលការជំនុំជម្រះ។ មិនមានឧទាហរណ៍ដែលពាក់ព័ន្ធនឹងជនជាប់ចោទស្ថិតក្នុងមន្ទីរឃុំឃាំងដែលលទ្ធភាពនៃការជំនុំជម្រះហាក់មិនអាចធ្វើទៅ បាននោះឡើយ(*សូមមើល* តារាងសំណុំរឿងនៃការឃុំខ្លួនជនជាប់ចោទនៅតុលាការ ICTY ICTR ដែលមានពី ៥ ទៅ ១០ឆ្នាំ (ឯកសារ E138/1/9.1 ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១២))។

២៣. ដូចដែលយុត្តិសាស្ត្រខាងលើបានចង្អុលបង្ហាញ ការបន្តឃុំខ្លួនជនជាប់ចោទដែលពុំមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ដើម្បីចូលរួមការជំនុំជម្រះអាចមានយុត្តិកម្ម លុះត្រាតែមានលទ្ធភាពខ្ពស់ដែលថា ជនជាប់ចោទអាចប្រែជាមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ដើម្បីចូលរួមសវនាការ នៅក្នុងពេលខាងមុខ ដែលគេអាចប្រមើលដឹង (និងលុះត្រាណាមានការរំពឹង ដោយមានហេតុផលត្រឹមត្រូវថា បុគ្គលនោះត្រូវបានជំនុំជម្រះ ដោយពុំមានការអូសបន្លាយពេលដែលពុំចាំបាច់)។

## ៦. សំអាងហេតុ

### <u>៦.១.</u> បច្ច័យដែលកើតចេញពីការ<u>រកឃើញពាក់ព័ន្ធនឹងសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានការវាយតម្លៃឡើងវិញរបស់អ្នកជំនាញ</u>

២៤. អង្គជំនុំជម្រះសាលាដំបូងបានទទួលរបាយការណ៍ដែលមានលទ្ធផលដូចៗគ្នា និងស៊ីសង្វាក់គ្នាដែលអ្នកជំនាញជាច្រើនបានរកឃើញថា ជនជាប់ចោទពិតជាទទួលរងនូវស្ថានភាពជំងឺវង្វេងស្មារតីដែលចេះតែវិវឌ្ឍន៍ទៅមុខ (ទំនងយ៉ាងខ្លាំងថាជាជំងឺ Alzheimer) ដែលពុំទំនងជាធូរស្រាលតាមរយៈការព្យាបាលបន្ថែមឡើយ។ ផ្អែកលើការរកឃើញរបស់អ្នកជំនាញទាំងនេះ អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ជាថ្មីអំពី សេចក្តីសន្និដ្ឋានពេលមុនរបស់ខ្លួនដែលថា ការបាត់បង់ការចងចាំរយៈពេលខ្លី និងរយៈពេលវែងរបស់ អៀង ធីរិទ្ធ ពិតជាធ្វើឱ្យគាត់ពុំមានសមត្ថភាពយល់ដឹងគ្រប់គ្រាន់អំពីការប្រព្រឹត្តទៅនៃកិច្ចដំណើរនីតិវិធី និងពុំអាចពិគ្រោះយោបល់ជាមួយមេធាវីបានគ្រប់ជ្រុងជ្រោយ និងពុំអាចចូលរួមក្នុងការការពារខ្លួនប្រកបដោយប្រសិទ្ធភាពបានឡើយ។ ការខិតខំប្រឹងប្រែងប្រើប្រាស់គ្រប់វិធានការទាំងអស់ដើម្បីធ្វើឱ្យប្រសើរឡើងនូវមុខងារខាងបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ ត្រូវបានធ្វើអស់លទ្ធភាពហើយ។ បន្ទាប់ពីទទួលបានការវាយតម្លៃរបស់អ្នកជំនាញថ្មីៗនេះបង្ហាញថា ជនជាប់ចោទនឹងមិនអាចមានសមត្ថភាពផ្តល់ចម្លើយនៅពេលជំនុំជម្រះបានទេ។ ការសាកល្បងព្យាបាលតាមគ្រប់វិធានការដែលអាចធ្វើទៅបានត្រូវបានយកមកប្រើប្រាស់អស់លទ្ធភាពហើយ។ ទោះបីជា មានការប្រើប្រាស់គ្រប់វិធានការហើយក្តី ជនជាប់ចោទនៅតែពុំអាចមានសមត្ថភាពក្នុងការអនុវត្តសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ប្រកបដោយអត្ថន័យឡើយ អង្គជំនុំជម្រះសម្រេចតម្កល់ជាថ្មីនូវសេចក្តីសម្រេចរបស់ខ្លួនពីលើកមុនដែលថា ជនជាប់ចោទពុំមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះ។ ជាងនេះ

ទៀតវា ហាក់ដូចជាគ្មានការរំពឹងសមហេតុផលដែលថា ការធ្លាក់ចុះខ្សោយខាងបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ អាចត្រូវបានធ្វើឱ្យប្រសើរឡើងវិញបានឡើយ។

២៥. បើទោះបីជាអង្គជំនុំជម្រះបានឃើញសេចក្តីសន្និដ្ឋានផ្ទុយពីនេះរបស់វេជ្ជបណ្ឌិត ចក ធីតា ក៏ដោយ ក៏អង្គជំនុំជម្រះកត់សម្គាល់ឃើញថា កាលពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ និងនៅក្នុងរបាយការណ៍របស់អ្នកជំនាញពួកគាត់ទាំងអស់គ្នាបានលើកឡើងអំពីចំណុចខ្វះចន្លោះជាច្រើនទាំងលើវិធីសាស្ត្រទាំងលើអង្គហេតុ និងទាំងលើការវិភាគជាក់លាក់មួយចំនួននៅក្នុងរបាយការណ៍បន្ទាន់របស់វេជ្ជបណ្ឌិត ចក ធីតា និងសក្ខីកម្មរបស់គាត់ នាពេលសវនាការ[57]។ ជាឧទាហរណ៍ បើទោះបីជាវេជ្ជបណ្ឌិត ចក ធីតា បានកត់សម្គាល់ឃើញអំពីការបាត់បង់ការចងចាំខ្លះៗក៏ដោយ ក៏គាត់បានសន្និដ្ឋានថា ជនជាប់ចោទពុំបានបង្ហាញសញ្ញាណាមួយនៃជំងឺផ្លូវចិត្តឡើយ[58]។ វេជ្ជបណ្ឌិត ចក ធីតា បានបដិសេធថា អៀង ធីរិទ្ធ មិនមានបញ្ហាខាងសមត្ថភាពគ្រប់គ្រងការបត់ជើងតូច និងជំងឺមមើមមាយនោះទេ បើទោះបីជាបញ្ហានេះត្រូវបានបញ្ជាក់អះអាងដោយឯករាជ្យពីសំណាក់អ្នកទទួលខុសត្រូវលើការថែទាំជនជាប់ចោទប្រចាំថ្ងៃក៏ដោយ[59]។ ថ្វីដ្បិតវេជ្ជបណ្ឌិត ចក ធីតា បានរាយការណ៍ថា អៀង ធីរិទ្ធ បានទទួលពិន្ទុចំនួន ២៤ លើ ៣០ ក្នុងការធ្វើតេស្ត MMSE កាលពីខែកក្កដា ឆ្នាំ ២០១២ ក៏ដោយ ក៏អ្នកជំនាញទាំងនេះបានកត់សម្គាល់ឃើញថា ពិន្ទុនេះពុំស៊ីសង្វាក់គ្នាជាមួយពិន្ទុតេស្ត MMSE ចំនួន ៨ ផ្សេងទៀតដែលបានធ្វើ កាលពីឆ្នាំ ២០១១ និងឆ្នាំ ២០១២ ឡើយ[60]។ អ្នកជំនាញទាំងនេះក៏បានកត់សម្គាល់ឃើញទៀតថា វេជ្ជបណ្ឌិត ចក ធីតា បានរៀបចំតេស្ត MMSE ពុំបានត្រឹមត្រូវ តាមរយៈការជំនួសសំណួរស្តង់ដារមួយចំនួន ដោយសំណួរផ្សេងៗដែលមានលក្ខណៈងាយស្រួលជាង[61]។ តេស្តនេះគឺតេស្តស្តង់ដារ ដោយផ្អែកលើគោលការណ៍

---

[57] ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៦២។

[58] ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៥០ ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២, ទំព័រ ៧៧។

[59] ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ២៤ ទំព័រ ២៦ ដល់២៧ ទំព័រ ២៩ ទំព័រ ៣១ និងទំព័រ ៣៦។

[60] ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៤៣ ដល់កថាខណ្ឌ ៤៤ (ផ្អែកលើការពិនិត្យរបាយការណ៍ដែលធ្វើឡើងដោយប្រធានមន្ទីរឃុំឃាំង អ្នកយាមជាស្ត្រី និងអ្នកព្យាបាលដោយចលនា ថា អៀង ធីរិទ្ធ មានបញ្ហាក្នុងការដឹងពេលបត់ជើងតូច និងមានការរវើរវាយ)។ បើទោះបីជាវេជ្ជបណ្ឌិត ចក ធីតា បានអះអាងថា សាស្ត្រាចារ្យ Campbell មិនបានរៀបរាប់ឱ្យបានត្រឹមត្រូវលើលទ្ធភាពរបស់ជនជាប់ចោទក្នុងការស្គាល់ប៊ិច ក្រោយមកធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងកំណត់ហេតុដែលបង្ហាញថា ការអះអាងនេះមិនត្រឹមត្រូវឡើយ (ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៨)។ ជាងនេះទៀត គាត់ខកខានមិនបានពិនិត្យប្រវត្តិរបស់ជនជាប់ចោទទៀតផង (ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៤០)។

[61] ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៤០។

00846954

ណែនាំដែលត្រូវបានគេទទួលស្គាល់ជាអន្តរជាតិ ហើយការកែប្រែណាមួយទៅលើតេស្តនេះនឹងគ្រាន់តែធ្វើឱ្យលទ្ធផលដែលទទួលបានត្រូវទុកជាមោឃៈប៉ុណ្ណោះ[62]។ វេជ្ជបណ្ឌិត ចក ធីតា ក៏ហាក់ដូចជាបានអនុវត្តពុំបានត្រឹមត្រូវនូវតេស្តដែលត្រូវបានរៀបចំ ដើម្បីវាយតម្លៃការស្គាល់អំពីពេលវេលា និងខកខានពុំបានប្រមូលប្រវត្តិព័ត៌មានពីអ្នកផ្តល់ព័ត៌មានផ្សេងទៀតទេ[63]។ ថ្វីបើគាត់ជឿថា ការវាយតម្លៃរបស់គាត់ទំនងជាមានភាពត្រឹមត្រូវជាងការវាយតម្លៃរបស់អ្នកជំនាញ ដោយសារគាត់មានទំនាក់ទំនងល្អប្រសើរជាមួយ អៀង ធីរិទ្ធ ក្នុងនាមគាត់ជាស្ត្រី និងជាអ្នកនិយាយភាសាខ្មែរក៏ដោយ ក៏ពុំមានសញ្ញាបញ្ជាក់អំពីការខ្វះទំនាក់ទំនងល្អរវាងអ្នកជំនាញ និងជនជាប់ចោទ ឬសញ្ញាបញ្ជាក់ថាជនជាប់ចោទឆ្លើយបានល្អជាង ទៅកាន់មនុស្សដែលមានភេទ និងវប្បធម៌ដូចគាត់ឡើយ[64]។ ទោះជាយ៉ាងណាក្តី វេជ្ជបណ្ឌិត ចក ធីតា បានឯកភាពថា មុខងារខាងបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ ពុំមានការល្អប្រសើរឡើងឡើយក្នុងអំឡុងពេលប៉ុន្មានខែកន្លងមកនេះ[65]។ តាមសំអាង ហេតុទាំងអស់នេះ អង្គជំនុំជម្រះយល់ឃើញថា របាយការណ៍របស់វេជ្ជបណ្ឌិត ចក ធីតា ឬសក្ខីកម្ម របស់គាត់បន្ទាប់ពីមានរបាយការណ៍នេះ ពុំបានធ្វើឱ្យសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញទាំងអស់នេះ មានមន្ទិលសង្ស័យឡើយ[66]។

## <u>៦.២. បច្ច័យនៃការមិនមានសមត្ថភាពខាងបញ្ញាស្មារតីគ្រប់គ្រាន់របស់ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ</u>

---

[62] ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៤០ (ដោយមានការបញ្ជាក់ថា ប្រសិនបើមានការដាក់ពិន្ទុបានត្រឹមត្រូវនោះ អៀង ធីរិទ្ធ អាចមានពិន្ទុច្រើនបំផុត ១៥ ក្នុងចំណោមពិន្ទុសរុប ៣០ នៅលើតេស្ត MMSE ដែលបានធ្វើឡើងដោយវេជ្ជបណ្ឌិត ចក ធីតា); ប្រតិចារិក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៤ ដល់ ៥ ទំព័រ ៧៧ ដល់ទំព័រ ៧៨។

[63] ប្រតិចារិក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៦៩។ ជាងនេះទៀត វេជ្ជបណ្ឌិត ចក ធីតា ហាក់ដូចជាអះអាងផ្ទុយទៅនឹងខ្លួនឯងផ្ទាល់ ដោយធ្វើការបញ្ជាក់ថា ក្នុងពេលជនជាប់ចោទមានភាពវ័យឆ្លាត និងមានការអប់រំខ្ពស់នោះ មិនចាំបាច់ធ្វើការកែសម្រួលតេស្ត ក្នុងការស្វែងរកព័ត៌មានទាក់ទងនឹងកម្រិតនៃការអប់រំរបស់គាត់ទេ ហើយជាលទ្ធផល ពុំមានឧបសគ្គក្នុងការប្រើប្រាស់តេស្តដែលបានកែសម្រួលបទដ្ឋានឡើយ (ប្រតិចារិក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៤៤ ដល់ ៤៥)។

[64] ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៤០។

[65] ប្រតិចារិក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៣២ ទំព័រ ៣៣, ទំព័រ ៨០; ប្រតិចារិក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៣ ទំព័រ ៦ ទំព័រ ៦៥ ដល់ ៦៦ (បង្ហាញថា អ្នកជំនាញបានរៀបចំឱ្យមានរបាយការណ៍មួយយ៉ាងល្អ ជាមួយនឹងជនជាប់ចោទ ហើយថា ជនជាប់ចោទមានអាកប្បកិរិយាដោយមានការមិនស្វាគមន៍ម្តងម្កាលចំពោះបុគ្គលិកស្ត្រីជនជាតិខ្មែរ នៅក្នុងមន្ទីរឃុំឃាំង)។ ជាងនេះទៀត លោកវេជ្ជបណ្ឌិត ហួត លើនណា ពេទ្យវិកលចរិតកម្ពុជា បានអះអាងស្របទៅនឹងការសន្និដ្ឋានរបស់អ្នកជំនាញអន្តរជាតិផ្សេងៗទៀត (ប្រតិចារិក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១ ទំព័រ ១១ ទំព័រ ៥៦)។

[66] ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៤០។

២៦. បន្ទាប់ពីមានការវាយតម្លៃឡើងវិញទៅលើជនជាប់ចោទ តាមការបង្គាប់របស់អង្គជំនុំជម្រះតុលាការកំពូល និងលទ្ធផលដូចគ្នារបស់អ្នកជំនាញទាក់ទិននឹងការធ្លាក់ចុះនៃបញ្ញាស្មារតីរបស់ជនជាប់ចោទ អង្គជំនុំជម្រះសម្រេចតម្កល់ជាថ្មីនូវសេចក្តីសម្រេចរបស់ខ្លួនកាលពីខែ វិច្ឆិកា ឆ្នាំ ២០១១ ដែលថា ជនជាប់ចោទ អៀង ធីរិទ្ធ ពិតជាពុំមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ដើម្បីចូលរួមការជំនុំជម្រះ។ ជនជាប់ចោទបានបន្តស្ថិតក្នុងមន្ទីរឃុំឃាំងចាប់តាំងពីកាលបរិច្ឆេទនោះមក និងពុំមានការរំពឹង សមហេតុផលក្នុងការយកជនជាប់ចោទរូបនេះមកជំនុំជម្រះ នៅពេលណាបាននោះទេ។ លើសពីនេះទៀត ការដោះលែងជនជាប់ចោទពីមន្ទីរឃុំឃាំង ពុំមានការជំទាស់ពីសហព្រះរាជអាជ្ញា ឬ មេធាវីការពារក្តីឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងពិនិត្យមើលឡើងវិញលើមូលដ្ឋានដែលកំណត់ដោយអង្គជំនុំជម្រះរបស់តុលាការកំពូលក្នុងការបន្តការឃុំខ្លួនជនជាប់ចោទ ដោយយោងទៅលើកាលៈទេសៈទាំងអស់នេះ។

២៧. មូលដ្ឋានដំបូងរបស់អង្គជំនុំជម្រះតុលាការកំពូលសម្រាប់បន្តការឃុំខ្លួនលោកស្រី អៀង ធីរិទ្ធ បានផ្អែកទៅលើការពិចារណាដែលថា ការបន្តព្យាបាលតាមអនុសាសន៍របស់អ្នកជំនាញវេជ្ជសាស្ត្រអាចធ្វើឱ្យ អៀង ធីរិទ្ធ មានសម្បទាខាងបញ្ញាស្មារតីអាចចូលរួមការជំនុំជម្រះ[67]។ ការព្យាបាលនោះ ក៏បានចប់សព្វគ្រប់ហើយដែរ ហើយអ្នកជំនាញផ្នែកវេជ្ជសាស្ត្របានសន្និដ្ឋានថា លោកស្រី អៀង ធីរិទ្ធ មានស្ថានភាពជំងឺវង្វេងស្មារតីកាន់តែធ្ងន់ធ្ងរ (ដែលទំនងយ៉ាងខ្លាំងថាជាជំងឺ Alzheimer) ដែលធុនធ្ងរជាងកាលពីឆ្នាំមុន បើទោះបីជាមានការអនុវត្តវិធានការបន្ថែម ដែលប្រើប្រាស់ដើម្បី ជួយទប់ការធ្លាក់ចុះបញ្ញាស្មារតីរបស់គាត់ក៏ដោយ។ បន្ថែមពីលើនេះ អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ បានបញ្ជាក់ថា មិនមានការព្យាបាលណាផ្សេង ដែលទំនងជាអាចធ្វើឱ្យសម្បទា

[67] ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៤៩ ដល់ទំព័រ ៥០។ បើទោះបីជាមានការបញ្ជាក់ថាមានបទពិសោធន៍នៃជំងឺវង្វេងវង្វាន់ក៏ដោយ ក៏វេជ្ជបណ្ឌិត ចក ធីតា មិនអាចបញ្ជាក់ឱ្យបានច្បាស់លាស់ពីលក្ខណៈ និងភាពល្អិតល្អន់នៃបទពិសោធន៍នេះឡើយ។ ផ្ទុយទៅវិញ អ្នកជំនាញម្នាក់មានការបណ្តុះបណ្តាល និងបទពិសោធន៍រាប់ទសវត្សរ៍ក្នុងការអនុវត្តវិកលចរិតវិទ្យាវេជ្ជសាស្ត្រ, វេជ្ជសាស្ត្រព្យាបាលមនុស្សចាស់ និងវិកលចរិតវិទ្យា (ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ១៥ ដល់ ២១); *មើលផងដែរ* ប្រវត្តិរូបសង្ខេបរបស់ Seena FAZEL, ឯកសារលេខ E111.4; ប្រវត្តិរូបសង្ខេបរបស់វេជ្ជបណ្ឌិត ហួត លីនណា ឯកសារលេខ E111.2 និងសេចក្តីសង្ខេបនៃគុណវុឌ្ឍិរបស់សាក្សីអ្នកជំនាញ, សាស្ត្រាចារ្យ Campbell ឯកសារលេខ E62.1 ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១១។

ខាងបញ្ញាស្មារតីរបស់ជនជាប់ចោទប្រសើរឡើងវិញបាន ដែលអាចធ្វើឱ្យគាត់អាចមានសម្បទាខាងបញ្ញាស្មារតី គ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះបានឡើយ[68]។

២៨. បើទោះបីជាអ្នកជំនាញយល់ឃើញថា មានលទ្ធភាពនៃការព្យាបាលតិចតួចបំផុតដែលអាចធ្វើឱ្យស្ថានភាពជំងឺ អៀង ធីរិទ្ធបានល្អប្រសើរឡើងវិញក៏ដោយ ក៏មតិភាគច្រើនលើសលុបរបស់អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា វិធានការវេជ្ជសាស្ត្រត្រូវតែប្រើប្រាស់ឱ្យអស់លទ្ធភាព មិនថាវិធានការនោះនាំមកនូវការធ្វើឱ្យប្រសើរឡើងក្នុងកម្រិតតិចតួចក៏ដោយ[69]។ ដោយសារតែមិនមានលទ្ធភាពក្នុងការព្យាបាលផ្នែកវេជ្ជសាស្ត្រណាផ្សេងទៀត ដែលអាចធ្វើឱ្យមុខងារខាងបញ្ញាស្មារតីរបស់ជនជាប់ចោទប្រសើរឡើងវិញបាន ឬ ដោយសារតែគ្មានលទ្ធភាពដែលថា ជនជាប់ចោទអាចនឹងមានភាពប្រសើរឡើងវិញបានដោយមិនចាំបាច់ព្យាបាល សេចក្តីសម្រេច ផ្អាកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានចេញកាលពីពេលមុនត្រូវបន្តដោយមិនកំណត់រយៈពេល[70]។ នៅក្នុងបរិបទនេះ ពាក្យ "មិនកំណត់រយៈពេល" មានន័យថា ផ្អាកកិច្ចដំណើរការនីតិវិធី

---

[68] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ដល់ ៤១ (ដោយកត់សម្គាល់ឃើញពីលទ្ធភាពនៃការព្យាបាលបន្ថែមដើម្បីជួយឱ្យជនជាប់ចោទមានសម្បទាក្នុងការចូលរួមសវនាការ និងសម្រេចថាជា "ការចាំបាច់ក្នុងការធានាឱ្យមានវត្តមានរបស់ជនជាប់ចោទក្នុងពេលសវនាការ នៅពេលមានការបើកសវនាការភ្លាម")។ ជាលទ្ធផលអង្គជំនុំជម្រះតុលាការកំពូលបានយល់ឃើញថា មូលហេតុដំបូងក្នុងការបន្តដាក់ឃុំឃាំងជនជាប់ចោទដែលបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ (ពោលគឺ ដើម្បីធានាឱ្យមានវត្តមានរបស់ជនជាប់ចោទក្នុងពេលសវនាការ) នៅតែ "មានសុពលភាព និងមានភាពពាក់ព័ន្ធ" (*មើល* សេចក្តីសម្រេចលើសំណើសុំឱ្យដោះលែងជាបន្ទាន់របស់ នួន ជា ខៀវ សំផន និងអៀង ធីរិទ្ធ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E50, កថាខណ្ឌ ៤១ (អនុវត្តវិធាន ៦៣(៣)(ខ)(iii))។

[69] ការវាយតម្លៃឡើងវិញរបស់អ្នកជំនាញវេជ្ជសាស្ត្រ កថាខណ្ឌ ៥៩។

[70] សេចក្តីសម្រេចលើកទីមួយស្តីពីសម្បទាក្នុងការចូលរួមសវនាការ កថាខណ្ឌ ៥៣ (ដោយធ្វើការដកស្រង់ពីសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញដែលថា "ឱសថាប្រភេទនេះ [Donezepil] ហាក់បីដូចជាមានឥទ្ធិពលតិចតួចប៉ុណ្ណោះក្នុងការធ្វើឱ្យស្ថានភាពរបស់គាត់មានភាពប្រសើរឡើង"); *មើលការប្រៀបធៀប* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ២៩ កថាខណ្ឌ ៣៨ និងកថាខណ្ឌ ៤០ (ដកស្រង់ចេញពីអនុសាសន៍នៃអង្គជំនុំជម្រះសាលាដំបូង ICTY ថា ជនជាប់ចោទដែលពុំមានសម្បទាក្នុងការចូលរួមសវនាការ គួរទទួលបានការព្យាបាល ពីព្រោះការព្យាបាលនេះអាចធ្វើឱ្យស្ថានភាពរបស់គាត់ "មានភាពប្រសើរឡើង"; *សូមមើលផងដែរ* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៣៥ (ដោយបានរៀបរាប់ថា ៣៣ ភាគរយនៃ Donepezil អាចជួយមុខងារបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធឱ្យមានភាពប្រសើរឡើង ដូចនេះ "មិនត្រូវបញ្ឈប់ការប្រើប្រាស់ឱសថនេះឡើយ")។ ឱសថ Donepezil ត្រូវបានយកមកប្រើ ពីថ្ងៃទី ០៨ ដល់ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ប៉ុន្តែត្រូវបានបញ្ឈប់ទៅវិញដោយសារវា

រហូតដល់មានការបង្គាប់របស់អង្គជំនុំជម្រះឱ្យបន្តកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ។ បច្ច័យដែលកើតឡើងចេញពីការណ៍នេះ គឺថា អង្គជំនុំជម្រះសាលាដំបូង មិនអាចអនុវត្តយុត្តាធិការរបស់ខ្លួនលើជនជាប់ចោទបានទេ ក្នុងរយៈពេលនៃការផ្អាកកិច្ចដំណើរការនីតិវិធីនេះ[71]។

២៩. បើទោះបីជាភាពរីកចម្រើន ចេះតែមានជាបន្តបន្ទាប់ខាងផ្នែកវិទ្យាសាស្ត្រសុខាភិបាលក្តី និងលទ្ធភាពដែលគេមិនអាចបដិសេធដែលថា ការព្យាបាលជំងឺវង្វេងស្មារតីដែលចេះតែចុះអន់ថយទៅៗ (ជាពិសេសជំងឺ Alzheimer) ដែល ជាយថាហេតុ អាចនឹងត្រូវបានគេរកឃើញក៏ដោយ ក៏ការណ៍នេះគ្រាន់តែជាការស្មានៗតែប៉ុណ្ណោះ ហើយការប៉ាន់ស្មាននេះមិនអាចយកមកធ្វើជាយុត្តិកម្មសម្រាប់ដកហូតសិទ្ធិសេរីភាពរបស់ជនជាប់ចោទដែលមិនមានសម្បទាខាងបញ្ញាស្មារតី គ្រប់គ្រាន់នេះបានទេ ឬក៏ឃុំខ្លួនជនជាប់ចោទរហូតបានទេ។ មានករណីដែល អង្គជំនុំជម្រះសម្រេចផ្ទុយពីនេះ តុលាការមិនអាចបង្គាប់ឱ្យដោះលែងឡើយ បន្ទាប់ពីបានរកឃើញសម្បទាខាងបញ្ញាស្មារតីមិនគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះ ដោយផ្អែកលើការប៉ាន់ស្មានផ្នែកវេជ្ជសាស្ត្រដែលថា ស្ថានភាពជំងឺដែលមិនអាចព្យាបាលបានពេលបច្ចុប្បន្ន ប៉ុន្តែប្រហែលជាអាចព្យាបាលបាននាពេលអនាគតនោះ។ ដោយសារតែមិនមានលទ្ធភាពសមហេតុផលដែលថា ជនជាប់ចោទ អៀង ធីរិទ្ធ អាចជាសះស្បើយពីជំងឺមុខងារខាងបញ្ញាស្មារតី ដែលអាចឱ្យគាត់មានសម្បទា ខាងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមសវនាការបាន នាពេលអនាគតខាងមុខនោះ អង្គជំនុំ ជម្រះយល់ឃើញថា ការបន្តឃុំខ្លួនជនជាប់ចោទដោយផ្អែកតាមកាលៈទេសៈបច្ចុប្បន្ននេះ នឹងរំលោភសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទ

៣០. បន្ថែមពីលើនេះ ក្របខ័ណ្ឌគតិយុត្តរបស់អ.វ.ត.ក មិនមានចែងអំពីមូលដ្ឋានច្បាប់ដើម្បីធ្វើជាយុត្តិកម្មក្នុងការបន្តឃុំខ្លួនជនជាប់ចោទ នៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះទេ។ បទប្បញ្ញត្តិនៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដែលដកស្រង់ដោយសហព្រះរាជអាជ្ញា ទាក់ទិននឹងការឃុំខ្លួនបណ្តោះអាសន្ន ឬការដោះលែងបណ្តោះអាសន្នក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាបទប្បញ្ញត្តិ ដែលត្រូវបានសន្មតជាមុនថានឹងមានការជំនុំជម្រះ នៅពេលអនាគតដែលគេអាចប្រមើលមើលឃើញជាមុន[72]។

---

បានធ្វើឱ្យជនជាប់ចោទក្អួត ដែលជាសញ្ញានៃប្រតិកម្មឱសថ (អនុសាសន៍របស់អ្នកជំនាញ, ទំព័រ ៣; *សូមមើលផងដែរ* ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២, ទំព័រ ៥២ ដល់ទំព័រ ៥៣)។

[71] *មើលការប្រៀបធៀប* សេចក្តីសម្រេចលើសម្បទាក្នុងរឿងក្តី *Strugar* កថាខណ្ឌ ២៧ ("នៅក្នុងករណីខ្លះ បញ្ហានៃការគ្មានសម្បទាក្នុងរយៈពេលមួយ អាចដោះស្រាយតាមរយៈការព្យាបាល ដើម្បីឱ្យអង្គជំនុំជម្រះអាចបន្តការសវនាការបន្ទាប់ពីការពន្យារពេល ឬការអាក់ខាន")។

[72] សេចក្តីសម្រេចឃុំខ្លួន *Lubanga* កថាខណ្ឌ ៣៦។

00846958

៣១. នៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះ ការឃុំខ្លួនបន្ត នឹងរំលោភបន្ថែមទៀតលើការការពារដែលមានចែងជាអន្តរជាតិ ប្រឆាំងនឹងការឃុំខ្លួនដោយ មិនកំណត់រយៈពេល និងរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយមិនមានការពន្យារពេលមិនសមហេតុផល។ ក្នុងខណៈដែលទទួលស្គាល់ភាពធ្ងន់ធ្ងរនៃបទចោទដែលមានចែងនៅក្នុងដីកាដំណោះស្រាយ អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថាការឃុំខ្លួនលោកស្រី អៀង ធីរិទ្ធ ជាបណ្តោះអាសន្នអស់រយៈពេល៤ឆ្នាំ១០ខែ ហើយប្រសិនបើបន្តឃុំខ្លួនជនជាប់ចោទតទៅទៀត ដោយមិនប្រាកដថានឹងមានការជំនុំជម្រះលើរូបគាត់នៅពេលណាមួយនោះនឹងរំលោភសិទ្ធិជាមូលដ្ឋាននានា[73]។ ផ្អែកតាមសំអាងហេតុទាំងនេះ អង្គជំនុំជម្រះសម្រេចឲ្យដោះលែងជនជាប់ចោទជាបន្ទាន់។

## <u>៦.៣. សហព្រះរាជអាជ្ញាស្នើសុំឲ្យមានវិធានការមួយចំនួន នៅពេល ដោះលែង</u>

៣២. ដើម្បីគាំទ្រដល់ការសម្រេចរបស់ខ្លួនក្នុងការបន្តឃុំខ្លួនជនជាប់ចោទ អង្គជំនុំជម្រះតុលាការកំពូលដោយមតិភាគច្រើនបានសម្រេចថា ការត្រួតពិនិត្យតាមផ្លូវតុលាការ អនុលោមតាមមាត្រា២២៣នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាអាចអនុញ្ញាតបាន ដោយអង្គជំនុំជម្រះសន្និដ្ឋានថា "[ដោយសារ]សាលាដំបូងត្រូវបានអនុញ្ញាតឲ្យអនុវត្តការឃុំខ្លួន ដូច្នេះជាការសមហេតុផលដែលតុលាការនេះ ត្រូវបានអនុញ្ញាតឲ្យអនុវត្តនូវវិធានការដែលពុំសូវរិតត្បិត"[74]។

៣៣. ក្រោយពីបានសន្និដ្ឋានថា មិនមានលទ្ធភាពសមហេតុផលដែលជនជាប់ចោទនឹងត្រូវបានយកមកជំនុំជម្រះ ក្នុងពេលអនាគតដែលគេអាចប្រមើលដឹង និង បានផ្អាកកិច្ច ដំណើរការនីតិវិធីដោយមិនកំណត់រយៈពេលលើរូបគាត់ អង្គជំនុំជម្រះសាលាដំបូងមិនមានមូលដ្ឋានគតិយុត្តិក្នុងការឃុំខ្លួនជនជាប់ចោទនេះបានទៀតទេ ដូចនេះ អង្គជំនុំជម្រះត្រូវមានកាតព្វកិច្ច ដោះលែងជនជាប់ចោទ។ ដោយ សារតែយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងលើជនជាប់ចោទត្រូវបានផ្អាក អង្គជំនុំជម្រះសាលាដំបូងមិនមានមូលដ្ឋានគតិយុត្តិច្បាស់លាស់ ដើម្បីកំណត់លក្ខខណ្ឌដោយបង្ខំ ឬដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការតាមទម្រង់ផ្សេងៗលើជនជាប់ចោទនៅពេលដោះលែងទេ។ សហព្រះរាជអាជ្ញាពឹងផ្អែករបៀបប្រៀបធៀបលើវិធាន ៦៥ និងវិធាន ៨២ នៃវិធានផ្ទៃក្នុង

---

[73] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ២៤ *(ដោយដកស្រង់ចេញពីសេចក្តីសម្រេចឃុំខ្លួន* *Lubanga* កថាខណ្ឌ ៣៧ (*ដោយលើកសំអាងពី* ICCPR, ECtHR, អនុសញ្ញាសហរដ្ឋអាមេរិកស្តីពីសិទ្ធិមនុស្ស និងធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិមនុស្ស)។ សូមមើលផងដែរកំណត់ហេតុសវនាការ ស្តីពីការបង្ហាញខ្លួនលើកដំបូង ឯកសារ E3/664 ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[74] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៤៥។

(ដែលទាក់ទិននឹងការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ និងការឃុំខ្លួនបណ្តោះអាសន្ន)។ បទប្បញ្ញត្តិទាំងនេះ មិនអាចយកមក ធ្វើជាមូលដ្ឋានសម្រាប់ដាក់លក្ខខណ្ឌដោយបង្ខំលើជនជាប់ចោទ ដែលទំនងជាមិនអាចយកមកជំនុំជម្រះវិញបាន ហើយដែលត្រូវបាន ដោះលែង និងដែលអង្គជំនុំជម្រះលែងមានយុត្តាធិការហើយនោះ[75]។ ប៉ុន្តែ សហព្រះរាជអាជ្ញា បានដកស្រង់យុត្តិសាស្ត្រអន្តរជាតិជាច្រើន ដើម្បីធ្វើជាយុត្តិកម្មក្នុងការកំណត់លក្ខខណ្ឌលើលោកស្រី អៀង ធីរិទ្ធ នៅពេលដោះលែង ដែលយុត្តិសាស្ត្រអន្តរជាតិភាគច្រើន ទាក់ទងនឹងស្ថានភាពអង្គហេតុខុសគ្នាពីអង្គហេតុនាពេលនេះ[76]។ មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ តវ៉ាថា យុត្តិសាស្ត្រអន្តរជាតិនេះ ដែលសម្រេចដាក់លក្ខខណ្ឌលើជនជាប់ចោទក្រោយពេលដោះលែងមិនមានមូលដ្ឋានគតិយុត្តិទេ[77]។

៣៤. នៅក្នុង*រឿងក្តី* *Kovacevic* អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY បានសម្រេចឱ្យដោះលែងជនជាប់ចោទជាបណ្តោះអាសន្ន ដើម្បីទទួលបានការព្យាបាលផ្នែកវេជ្ជសាស្ត្រ "ដើម្បីបញ្ជាក់ថាតើជនជាប់ចោទអាចមានសម្បទាខាងបញ្ញាស្មារតី ក្នុងការចូលរួមការជំនុំជម្រះនាពេលអនាគតដែរ ឬយ៉ាងណា ក្រោយពេលទទួលបានការព្យាបាលគ្រប់គ្រាន់"[78]។ គោលបំណងដោះលែងជាបណ្តោះអាសន្ន គឺដើម្បីអនុញ្ញាតឱ្យមានការព្យាបាលផ្នែកវេជ្ជសាស្ត្រ "រហូតដល់ពេលដែលអង្គជំនុំអាចសម្រេចជាស្ថាពរលើសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទក្នុងការចូលរួមការជំនុំជម្រះ"[79]។ ក្នុងខណៈដែលលទ្ធភាពនៃការជំនុំជម្រះនាពេលអនាគតនៅក្នុងរឿងក្តី *Kovacevic* អាចធ្វើជាយុត្តិកម្មក្នុងការកំណត់លក្ខខណ្ឌនៅពេលដោះលែងគាត់ក៏ដោយ ក៏ករណីរឿងក្តី *Kovacevic* មិនដូចគ្នានឹងបរិបទបច្ចុប្បន្ននេះទេ។ នៅក្នុងរឿងក្តីបច្ចុប្បន្ននេះជម្រើសនៃការព្យាបាលផ្នែកវេជ្ជសាស្ត្រ ដើម្បីឱ្យមុខងារខាងបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ បានប្រសើរឡើងត្រូវបានប្រើប្រាស់អស់លទ្ធភាពហើយ ហើយអង្គជំនុំជម្រះសាលាដំបូងបានសម្រេចជាចុងក្រោយលើសម្បទាខាងបញ្ញាស្មារតី របស់ជនជាប់ចោទ។

---

[75] ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ១០៣ ដល់ ១០៤។

[76] ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ១០១ ដល់ ១០២។

[77] ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ១៣១។

[78] រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Vladimir Kovačević*, IT-01-42/2-I, "សេចក្តីសម្រេចលើការដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន" ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០០៤ ("សេចក្តីសម្រេចលើការដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន ក្នុងរឿងក្តី *Kovačević*"), ទំព័រ ១។

[79] សេចក្តីសម្រេចលើការដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន ក្នុងរឿងក្តី *Kovacevic* ទំព័រ ២។

៣៥. នៅក្នុងរឿងក្តី Talic មានភាពខ្វែងគំនិតគ្នាក្នុងចំណោមអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ចំពោះថាតើជនជាប់ចោទ Talic មានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ដើម្បីចូលរួមសវនាការដែរ ឬយ៉ាងណា[80]។ ទោះបីជាមានការបដិសេធមិនធ្វើសេចក្តីសម្រេចស្ថាពរ លើបញ្ហានៃសម្បទាខាងបញ្ញាស្មារតីយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានដោះលែងជនជាប់ចោទជាបណ្តោះអាសន្ន ដោយផ្អែកលើហេតុផលថា ស្ថានភាពវេជ្ជសាស្ត្ររបស់គាត់ គឺ "មិនស៊ីសង្វាក់គ្នាជាមួយនឹងស្ថានភាពនៃការឃុំខ្លួនបន្តឡើយ"[81]។ ការដាក់លក្ខខណ្ឌទៅលើការដោះលែងរូបគាត់ ក៏ត្រូវបានធ្វើយុត្តិកម្មផងដែរ ដោយលទ្ធភាពដែលថា ជាយថាហេតុ គាត់នឹងអាចចូលរួមការជំនុំជម្រះបាន ហើយអង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ទៀតថា ជនជាប់ចោទ បានយល់ព្រមទៅនឹងការដាក់លក្ខខណ្ឌទាំងនេះ[82]។ ផ្ទុយទៅវិញ កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានផ្អាកដោយមិនកំណត់រយៈពេល ហើយមេធាវីការពារក្តីរបស់លោកស្រីជំទាស់ទៅនឹងការដាក់លក្ខខណ្ឌក្រោយការដោះលែង។

៣៦. ទោះបីជាគណៈកម្មការពិសេសនៅក្នុងតុលាការទីម័រខាងកើត បានដាក់លក្ខខណ្ឌទៅលើការដោះលែងជនជាប់ចោទដែលពុំមាន សម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ យ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះមិនបានផ្តល់យុត្តិកម្មគតិយុត្តិចំពោះការបន្តនូវវិធានការទាំងនោះឡើយ បន្ទាប់ពីរឿងក្តីនោះត្រូវបានផ្អាកដោយមិនកំណត់រយៈពេល (*sine die*)[83]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក៏បានដោះលែងជនជាប់ចោទ Djukic ជាបណ្តោះអាសន្នផងដែរ ដោយបានរកឃើញថា គាត់បានទទួលរងនូវជំងឺដែលមិនអាចព្យាបាលបាន ហើយនឹងទទួលរងនូវ "ការធ្លាក់ចុះជុនដាបសម្បទាខាង

[80] រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Radoslav Brđjanin and Momir Talić*, សេចក្តីសម្រេចលើ ញត្តិស្នើសុំការដោះលែងនៅក្រៅឃុំបណ្តោះអាសន្នជនជាប់ចោទ Momir Talić, អង្គជំនុំជម្រះសាលាដំបូង ICTY II (IT-99-36-T), ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០២ ("សេចក្តីសម្រេចលើការដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន ក្នុងរឿងក្តី *Talić*") កថាខណ្ឌ ២ កថាខណ្ឌ ៩។

[81] សេចក្តីសម្រេចលើការដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន ក្នុងរឿងក្តី *Talić* កថាខណ្ឌ ៣២។

[82] សេចក្តីសម្រេចលើការដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន ក្នុងរឿងក្តី *Talić* កថាខណ្ឌ ៣៤ កថាខណ្ឌ ៤២។

[83] រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Nahak,* សំអាងហេតុ និងដីកាស្តីពីសមត្ថភាពរបស់ជនជាប់ចោទ *Nahak* ក្នុងការចូលរួមសវនាការ, តុលាការស្រុក Dili (សំណុំរឿង លេខ 01A/2004) ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០០៥ ("សេចក្តីសម្រេចលើសម្បទារបស់ *Nahak*") កថាខណ្ឌ ១៦២ ដល់ ១៦៣ (*ដោយកត់សម្គាល់ឃើញថា* វាជា "ការសមស្រប" ក្នុងការបន្តប្រើប្រាស់វិធានការវិតត្បិតជំនួសនានា)។

បញ្ហាស្មារតីដែលមិនអាចជៀសផុតបានឡើយ”[84]។ ទោះបីជាអង្គជំនុំជម្រះបានដាក់លក្ខខណ្ឌក្នុងកម្រិតអប្បបរមាលើការដោះលែងរូបគាត់យ៉ាងណាក៏ដោយ (ដូចជា តម្រូវឱ្យរាយការណ៍អំពីអាសយដ្ឋានរបស់គាត់ ដាក់ជូននូវរបាយការណ៍វេជ្ជសាស្ត្រ តាមកាលកំណត់ស្ដីអំពីស្ថានភាពសុខភាពរបស់គាត់ និងឆ្លើយតបទៅនឹងដីកាកោះរបស់តុលាការ ប្រសិនបើស្ថានភាពវេជ្ជសាស្ត្ររបស់គាត់មានលក្ខណៈល្អប្រសើរអាចធ្វើទៅបាន) ក៏សេចក្ដីសម្រេចលើរឿងក្ដី Talic ក្រោយមកទៀតបានកំណត់ការដោះលែង Djukic ថាជាការដោះលែង “ពុំមានលក្ខខណ្ឌតាមសភាពជាក់ស្ដែង”[85]។

៣៧. ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញ ថា ពុំមានករណីណាមួយក្នុងចំណោមករណីដែលបានរៀបរាប់ខាង លើនេះគាំទ្រដល់ការដាក់លក្ខខណ្ឌលើការដោះលែង ក្នុងកាលៈទេសៈដូចជារឿងក្ដីនេះឡើយ។ ប៉ុន្តែករណីទាំងនេះពិតជាបានបង្ហាញនូវវិធានការជាក់លាក់មួយចំនួន ដែលអាចប្រើប្រាស់ជាលក្ខខណ្ឌសម្រាប់ការដោះលែង ដែលមានលក្ខណៈសមស្របសម្រាប់រឿងក្ដីនេះ។ ក្នុងស្ថានភាពវេជ្ជសាស្ត្ររបស់ជនជាប់ចោទ អៀង ធីរិទ្ធ លក្ខខណ្ឌដោយបង្ខំ នៅក្នុងករណីណាក៏ដោយ គឺតាមសភាពជាក់ស្ដែង ឬតាមផ្លូវច្បាប់ទំនងជាមិនអាចអនុវត្តបានឡើយ។ ឧទាហរណ៍ វាមានមន្ទិលថាតើជនជាប់ចោទនឹងអាចមានលទ្ធភាពបណ្ដុះនូវចេតនារំលោភទៅលើលក្ខខណ្ឌដែរឬយ៉ាងណា ឬថាតើ អាចមានការដាក់ទោសទណ្ឌឱ្យបានត្រឹមត្រូវលើរូបគាត់ ដែរ ឬយ៉ាងណា នៅពេលមានការរំលោភបំពានលក្ខខណ្ឌទាំងនោះ។ ដោយត្រូវបានដោះលែងពីមន្ទីរឃុំឃាំងដោយមូលហេតុអសមត្ថភាពផ្នែកបញ្ហាស្មារតីវាមិនមានភាពជាក់ស្ដែង (សហព្រះរាជអាជ្ញាក៏បានទទួលស្គាល់) ថាជនជាប់ចោទ អាចប្រឈមនឹងលទ្ធភាពនៃការឃុំខ្លួនជាថ្មីឡើងវិញ ចំពោះការរំលោភបំពានលក្ខខណ្ឌនានា ដែលគាត់ពុំមានសមត្ថភាពក្នុងការយល់ដឹង ឬក្នុងការប្រតិបត្តិតាមនោះ[86]។

---

[84] រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង *Djordje Djukić*, សេចក្ដីសម្រេចច្រានចោលពាក្យសុំដកដីកាចោទប្រកាន់ និងដីកាសុំ ការដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន, អង្គជំនុំជម្រះសាលាដំបូង ICTY (IT-96-20-T), ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦ (“សេចក្ដីសក្នុងរឿងក្ដី *Djukić* លើការដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន”) ទំព័រ ៣។

[85] សេចក្ដីសក្នុងរឿងក្ដី *Talić* លើការដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន កថាខណ្ឌ ៣២ (ទាក់ទងនឹងសេចក្ដីក្នុងរឿងក្ដី *Djukić* លើការដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន ទំព័រ ៤)។

[86] វាក៏មិនអាច ឬមានហេតុផលក្នុងការដាក់ពិន័យដូចនេះប្រឆាំងនឹងអ្នកឃាម ប្រសិនបើអ្នកឃាមរូបនោះត្រូវបានចាត់តាំងយោងតាមក្របខ័ណ្ឌច្បាប់កម្ពុជា ដោយផ្អែកលើមូលដ្ឋានថា ផ្នែក ១១១៤ ដល់ ១១១៥ និងផ្នែក ១១១៩ នៃក្រមស៊ីវិលកម្ពុជាត្រូវបានរៀបចំឡើង ដើម្បីការពារទ្រព្យសម្បត្តិរបស់បុគ្គលដែលមានពិការភាពផ្នែកខាងរាងកាយ ឬមានបញ្ហាបញ្ហាស្មារតី និងផ្ដល់ការថែទាំវេជ្ជសាស្ត្រ។ អ្នកឃាមទាំងនេះមិនត្រូវបានដាក់ឱ្យឃាមក្នុងគោលបំណងធានាឱ្យមានការគោរពតាមការរឹតត្បិតនានាដល់សេរីភាពរបស់ជនជាប់ចោទនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ។



ᵍᵗ Rf

00846962

៣៨. តាមហេតុផលដែលបានបញ្ជាក់ខាងលើ លក្ខខណ្ឌដោយបង្ខំគឺមិនមានភាពជាក់ស្តែង និង មិនអាចអនុវត្តបានឡើយ នៅក្នុងបរិបទនេះ។ ប៉ុន្តែ អង្គជំនុំជម្រះមិនជំទាស់ទៅនឹងវិធានការណ៍ជាច្រើនដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញានោះទេ នៅពេលដោះលែង។ ឧទាហរណ៍ កាតព្វកិច្ចរបស់ជនជាប់ចោទ ដោយមិនត្រូវជ្រៀតជ្រែកកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ដោយមិនត្រូវទាក់ទងដោយផ្ទាល់ ឬដោយប្រយោលជាមួយសាក្សី អ្នកជំនាញ ឬជនរងគ្រោះ ដែលត្រូវកោះហៅដោយអង្គជំនុំជម្រះ ឬ មិនត្រូវទាក់ទងដោយផ្ទាល់ ឬ ដោយប្រយោលជាមួយជនជាប់ចោទ លើកលែងតែស្វាមីរបស់គាត់ អៀង សារី គឺមានលក្ខណៈស្របតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ហើយអង្គជំនុំជម្រះក៏បានបញ្ជាក់ដែរ។ អង្គជំនុំជម្រះក៏បានពិចារណាផងដែរថា វាមានលក្ខណៈសមស្របក្នុងការស្នើឱ្យជនជាប់ចោទ អៀង ធីរិទ្ធ មិនត្រូវជួបជាមួយប្រព័ន្ធសារព័ត៌មានពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២។

៣៩. ស្ថានភាពលំបាក និងការចំណាយជាក់ស្តែង ដែលមានដោយការបន្តវាយតម្លៃឡើងវិញនូវសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ (ខណៈដែលការចង្អុលបង្ហាញរបស់អ្នកជំនាញថា ស្ថានភាពជម្ងឺរបស់ អៀង ធីរិទ្ធ មិនអាចព្យាបាលបាន និង មិនអាចវិលត្រឡប់មកសភាពធម្មតា វិញបាន) ដែលត្រូវបានស្នើឱ្យអ្នកជំនាញដែលត្រូវបានចាត់តាំងដោយតុលាការធ្វើក្នុងរយៈពេល០៦(ប្រាំមួយ) ខែម្តងនោះ គឺមិនមានលក្ខណៈសមស្របទេ។ ប៉ុន្តែ អង្គជំនុំជម្រះមានចេតនាការពិគ្រោះយោបល់ជាទៀងរាល់ឆ្នាំ ជាមួយអ្នកជំនាញ ដើម្បីបញ្ជាក់អំពីលទ្ធភាពនៃការរកឃើញនូវការព្យាបាលតាមបែបវេជ្ជសាស្ត្រថ្មីៗ ដែលតាមយោបល់របស់អ្នកជំនាញថា អាចនឹងជួយស្តារ សម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទឱ្យចូលរួមក្នុងការជំនុំជម្រះវិញបាន។ ការពិគ្រោះ យោបល់នេះនឹងត្រូវធ្វើជាទៀងរាល់ឆ្នាំ ដោយចាប់ផ្តើមពីខែ មីនា ឆ្នាំ ២០១៣ និង បន្តក្នុងរយៈពេលអត្ថិភាពនៃ អ.វ.ត.ក ។

៤០. ទោះបីជាកិច្ចដំណើរការនីតិវិធីជំនុំជម្រះប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានផ្អាកដោយមិនកំណត់រយៈពេលដោយសារតែបច្ច័យខាងលើក៏ដោយ ក៏អង្គជំនុំជម្រះ សូមបញ្ជាក់ថា បទចោទប្រឆាំងនឹងជនជាប់ចោទនៅតែមាន ហើយសេចក្តីសម្រេចនេះពុំមែនសម្រេចអំពីអត្ថិភាព ឬនត្ថិភាពនៃពិរុទ្ធភាពរបស់ជនជាប់ចោទឡើយ ទាក់ទិននឹងបទចោទប្រឆាំងនឹងជនជាប់ចោទនេះ នៅក្នុងសំណុំរឿង ០០២។

**ហេតុដូច្នេះ តាមសម្អាងហេតុខាងលើ អង្គជំនុំជម្រះ ៖**

**តម្កល់ជាថ្មី** សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងថា ជនជាប់ចោទ អៀង ធីរិទ្ធ មិនមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះ ។

**តម្កល់** ការបំបែកកិច្ចដំណើរការនីតិវិធីនូវបទចោទប្រកាន់នានាប្រឆាំងនឹងជនជាប់ចោទចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០២ ដោយអនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង។

**ប្រកាស** បន្តផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងសំណុំរឿង ០០២ ដោយមិនកំណត់រយៈពេល។

**បង្គាប់** ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក ជាបន្ទាន់។

**រំលឹកដល់** ជនជាប់ចោទនូវកាតព្វកិច្ចរបស់ខ្លួន ស្របតាមវិធាន៣៥ នៃវិធានផ្ទៃក្នុង មិនឲ្យធ្វើការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ហើយជាពិសេស មិនត្រូវជ្រៀតជ្រែកដល់សាក្សី អ្នកជំនាញ ឬ ជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក រួមទាំងជនជាប់ចោទដទៃទៀត លើកលែងតែស្វាមីរបស់គាត់ អៀង សារី និង ស្នើបន្ថែមមិនឲ្យជនជាប់ចោទជួបជាមួយប្រព័ន្ធសារព័ត៌មានពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ។

**ស្នើឲ្យ** ជនជាប់ចោទស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា និង ឲ្យជនជាប់ចោទ ឬ អ្នកអាណាព្យាបាលរបស់ជនជាប់ចោទជូនដំណឹងដល់ការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក មុននឹងផ្លាស់ប្តូរអាសយដ្ឋានរស់នៅណាមួយរបស់ជនជាប់ចោទ អៀង ធីរិទ្ធ។

**កត់សម្គាល់ថា** អង្គជំនុំជម្រះសាលាដំបូងមិនមានយុត្តាធិការទាក់ទងនឹងក្រមរដ្ឋប្បវេណីកម្ពុជាក្នុងការចាត់តាំងអ្នកអាណាព្យាបាលសម្រាប់ជនជាប់ចោទរូបនេះទេ ផ្ទុយទៅវិញ សមត្ថកិច្ចក្នុងការចាត់តាំងអ្នកអាណាព្យាបាលសម្រាប់ជនជាប់ចោទរូបនេះ គឺជាសមត្ថកិច្ចផ្តាច់មុខរបស់តុលាការជាតិកម្ពុជា។

**រៀបចំឲ្យមាន** ការពិគ្រោះយោបល់ជាមួយអ្នកជំនាញជារៀងរាល់ឆ្នាំដោយចាប់ផ្តើមពីខែមិនា ឆ្នាំ ២០១៣ និង បន្តក្នុងរយៈពេលអត្ថិភាពនៃ អ.វ.ត.ក ដើម្បីបញ្ជាក់អំពីលទ្ធភាពនៃជំរើសនៃការព្យាបាលថ្មី

ឬវិធីព្យាបាលដោយចលនាថ្មីចំពោះជម្ងឺវង្វេងស្មារតីនេះ (ជាពិសេសជំងឺអាល់ហ្សៃមែរ Alzheimer) ដែលអាចត្រូវបានរកឃើញ ហើយដែលតាមមតិយោបល់ជំនាញថា អាចនឹងជួយស្តារសមត្ថភាពខាងបញ្ញាស្មារតីរបស់ជនជាប់ចោទដល់កម្រិតមួយដែលជនជាប់ចោទអាចនឹងមានសម្បទាខាងបញ្ញាស្មារតីចូលរួមក្នុងការជំនុំជម្រះវិញបាន ។

**បដិសេធ** សំណើសុំដាក់វិធានការដទៃទៀតរបស់សហព្រះរាជអាជ្ញា។

**បដិសេធ** សំណើសុំឲ្យចាត់តាំងក្រុមអ្នកជំនាញថ្មីរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**កត់សម្គាល់ថា** សេចក្តីសម្រេចនេះអាចប្តឹងសាទុក្ខបាន ស្របតាមវិធានផ្ទៃក្នុង និងច្បាប់ជាធរមាន។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

និល ណុន